Free
សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA
E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 1 (267) 253-3947

មាតិការរឿង

Vol 07 Issue 133-July 13th- 26th. 2013

ទំព័រ

១-បច្ចុប្បន្នភាពនៃផែនការអភិវឌ្ឍន៍..................០៣
២-ខ្មែរកជាតិនិយម..........................................០៤
៣-ក្លូបបលវតណេសរាយការណ៍ពីបរិស្ថាន..........០៥
៤-The Cambodia daily....................០៦
៥- ខ្មែរផុសស្វាគមន៍គ្រួសារខ្មែរដែលប្រឹងប្រែង.....១៤
៦-វិស្វកម្មក្នុងចិត្តមនុស្ស.................................១៥
៨-ហោរាសាស្ត្រប្រចាំឆ្នាំ.................................១៧

New Office: Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

## វិភាគនយោបាយ
# ស្ថានភាពនយោបាយខ្មែរ បានផ្លាស់ប្តូរ



**ដោយ ពិន សំខុន**

នៅ២អាទិត្យមុនបោះឆ្នោតជាតិនៅកម្ពុជាវិភាគលើស្ថានភាពឃោសនាលើកនេះចង្អុលបង្ហាញថា នឹងមានចរន្តផ្លាស់ប្តូរយ៉ាងសំខាន់មួយដែលនឹងមកដល់ហើយ ដែលពលរដ្ឋខ្មែររង់ចាំតាំងពីឆ្នាំ១៩៩៣មក ។ ស្ថានភាពនោះ គឺការបោះឆ្នោតដែលនឹងមានលទ្ធផលថ្មីផ្ទុយពីទម្លាប់រង់ចាំពីនយោបាយ "ឈ្នះឈ្នះ" របស់គណបក្សប្រជាជន ។ ហេតុអ្វី? **តទៅទំព័រទី១៦**

## ព័ត៌មានខ្លីៗ...
# ប្រូវីដេន ធ្វើបុណ្យបញ្ចុះសីមា



ប្រជាពលរដ្ឋខ្មែរជាពុទ្ធបរិស័ទនៅប្រូវីដេន រដ្ឋរ៉ូដអៃឡិន បានមូលមតិសាមគ្គីគ្នាបង្កើតវត្តថ្មីមួយជាវត្តគម្រប់ទី៤ ឈ្មោះ "វត្តមណ្ឌលពុទ្ធសាសនា"ដែលទើបនឹងធ្វើបុណ្យបញ្ចុះសីមាហើយ កាលពីថ្ងៃទី២៣ មិថុនា ឆ្នាំ២០១៣ នេះ ក្នុងបរិយាកាសដ៏អធិកអធម ។ ព្រះតេជគុណ យៀង សុចិត្រា ជាចៅអធិការ និងគណៈកម្មាការដែលមានប្រធានកិត្តិយសនាមលោក ឡាយ ហ៊ី ប្រធានប្រតិបត្តលោក សៅ ធា អនុប្រធានលោក សំ សុវណ្ណ និងអាចារ្យវត្ត ម៉ី ជួន បានចេញសេចក្តីប្រកាសថា "វត្តនេះបានចាច់បដិសន្ធិតាំងពីឆ្នាំ១៩៩៩ **តទៅទំព័រទី ០៥**

## ដំណឹងចុងក្រោយ.............
# សម រង្ស៊ី នឹងទៅដល់ប្រទេសកម្ពុជាដោយសុវត្ថិភាព



-នៅមុនពេលកាសែតយើងចូលរោងពុម្ពប៉ុន្មាននាទីដំណឹងថ្មីមួយទៀតបានធ្លាក់មកដល់ គឺលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានស្នើសុំឱ្យព្រះមហាក្សត្រលើកលែងទោសដល់លោក សម រង្ស៊ី ហើយលិខិតលើកលែងទោសនោះ បានទទួលឡាយព្រះហស្ថលេខារួចហើយ នាព្រឹកថ្ងៃ សុក្រ ទី១២ កក្កដា នេះរួចហើយ ។

-ដំណឹងមួយទៀត ស្តីពីគ.ជប លោក អ៊ឹម សួស្តី **តទៅទំព័រទី ០៧**

ការិយាល័យ មេធាវី
ថំមាស ស្តាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
Immigration • Divorce • Auto Crash
▸ អន្តោប្រវេសន៍ ▸ គ្រោះថ្នាក់រថយន្ត ▸ លែងលះប្តីប្រពន្ធ
Call: Sophea or Thomas សូមទូរស័ព្ទមកៈ សោភា ឬធំ
978-459-5000 or 800-308-3766
Only Licensed in Massachusets

សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA
Grand Opening
7/18/13
កម្មវិធីសម្ពោធការិយាល័យថ្មីខ្មែរផុស ស.រ.អា យើងខ្ញុំមានសេចក្តីរីករាយសូមជម្រាបសាធារណជនថា ពិធីកាត់ខ្សែបូរណ៍សម្ពោធការិយាល័យថ្មីរបស់កាសែតខ្មែរផុស ស.រ.អា នឹងប្រព្រឹត្តទៅតាមកាលបរិច្ឆេទ និងទីកន្លែងដូចខាងក្រោម :
Please Join Us for
Ribbon Cutting
July 18th, 2013 at 4PM
45 Merrimack Street. Suite 218A
Lowell, MA 01852
• Refreshments
• KhmerPost USA Showcases.
មានទទួលស្វាគមន៍ដោយភេសជ្ជៈ
ពិព័រណ៍កាសែតខ្មែរផុស




ប្រើធនាគារឲ្យប្រសើរ
គឺនៅក្នុងកាបូប
FREE
$150 gift card
to Coach®
កាតរង្វាន់$150ទិញកាបូបល្បីឈ្មោះ"ខូច"
ជាមួយការបើកសេវាសម្រាប់ប្រើធនាគាររាល់ថ្ងៃ
Washington
SAVINGS BANK
washingtonsavings.com
* Restrictions apply
Ask for details.
Customer will receive a free gift within 30 days after redeeming a "FREE GIFT Certificate" and implementing the following combination of new services after 12/10/2012: A monthly direct deposit of at least $1,000 from an unaffiliated third party, at least one monthly automatic withdrawal that is not web or card based and an active debit card with 12 or more completed purchases is eligible for a $150 Coach® gift certificate. Promotion ends 06/30/2013. Coach® is a trademark of Coach, Inc. The program is not endorsed by Coach, Inc. nor is there any actual or implied joint venture, partnership or relationship of any kind between Washington Savings Bank and Coach, Inc. Promotions cannot be combined, one gift per customer, per account, per household. Available to personal accounts only. Fee of $150 applies for account closure or change of services within 6 months of free gift receipt. Washington Savings Bank reserves the right to disqualify any account/ person from this promotion if, in its sole discretion, it determines the account and/or services are solely designed to qualify for the free gift. Limited time offer, while supplies last.

# បច្ចុប្បន្នភាពនៃផែនការអភិវឌ្ឍន៍ក្រុងខ្មែរឡូវែល

**ដោយ សេងលី គង់**

សាលាក្រុងឡូវែលគ្រោងដាក់ផ្លាកសញ្ញាក្រុងខ្មែរដែលមានទ្រង់ទ្រាយជារូបខ្លែងឯកខ្មែរ (រូបទី១) លើបង្គោលផ្សាយពាណិជ្ជនៅក្បាល



ស្ពានផ្លូវ Middlesexជាអចិន្ត្រៃ ។ កាលពីថ្ងៃទី២៤ ខែឧសភា គណៈកម្មការក្រុងខ្មែរបានជួបប្រជុំជាមួយមន្ទីរផែនការក្រុងដើម្បីពិនិត្យ និងផ្តល់យោបល់លើរចនាបទ និងទិដ្ឋភាពវប្បធម៌ដែលទាក់ទងនឹងផ្លាកសញ្ញា។ លោក តុលាយុទ្ធ អនុប្រធានគណៈកម្មការ និងលោក ខៃ វឌ្ឍា ជាលេខាធិការបានផ្តល់យោបល់ល្អៗដល់សាលាក្រុងដើម្បីកែលម្អផ្លាកសញ្ញាដែលគូសព្រាងដោយសាលាក្រុង ។ ក្រៅពីពិភាក្សាការងារបច្ចេកទេសគណៈកម្មការក៏បានសួរនាំអំពីបរិច្ឆេទនៃការតំឡើងផ្លាកសញ្ញានេះ ។ អ្នកស្រី Diane Tradd អនុប្រធានមន្ទីរផែនការ និងអភិវឌ្ឍន៍សាលាក្រុងបានបញ្ជាក់ថា ផ្លាកសញ្ញារូបខ្លែងឯកខ្មែរបុរាណនេះនឹងត្រូវតម្លើងលើបង្គោលដងគោមក្នុងខែតុលា ឆ្នាំ២០១៣ខាងមុខនេះ ។

សាលាក្រុងក៏នឹងដាក់ពង្រាយបន្ថែមបដាសំយុង (Fig2) ចំនួន១៦ ផ្ទាំងទៀតនៅតាមផ្លូវសំខាន់ៗដែលមានពាណិជ្ជកម្មខ្មែរអាមេរិកាំង ដូចជា Middlesex nad Branch, ផ្លូវ Westford នៅម្តុំ Cupplesquare ជាដើម ។ បដាសំយុងទាំង១៦ផ្ទាំងនេះ នឹងត្រូវដំឡើងជាស្ថាពរក្នុងខែកញ្ញាឆ្នាំ២០១៣ ។




ចំណែកឯកៅអីវែង (Benches) ចំនួន១០កៅអី និងធុងសំរាមសាធារណៈចំនួន៤ធុង (Fig.3) ក៏នឹងត្រូវដាក់ពង្រាយក្នុងក្រុងខ្មែរឡូវែល ក្នុងពេលឆាប់ៗនេះដែរ ។ អ្នកស្រី Diane Tradd ក៏បានបញ្ជាក់ថា ការដាក់ពង្រាយកៅអី និងធុងអនាម័យសាធារណៈនឹងចាប់ផ្តើមក្នុងខែកក្កដា ឆ្នាំ២០១៣នេះ ។

តាមផែនការដើមសាលាក្រុងត្រូវបញ្ចប់កិច្ចការដាក់ពង្រាយរចនាសម្ព័ន្ធរូបវន្តទាំងនេះជាស្ថាពរតាំងពីខែ វិច្ឆិកា ឆ្នាំ២០១២ មកម្ល៉េះតែត្រូវបានពន្យាពេលដោយគ្មានមូលហេតុច្បាស់លាស់ ។ លោក វ៉ាស្នា នួន សមាជិកក្រុមប្រឹក្សាក្រុងឡូវែលមានការស្រងាកចិត្តជាខ្លាំង ចំពោះការយឺតយ៉ាវនេះ ។ លោក វ៉ាស្នា នួន បានផ្តាំផ្ញើឱ្យគណៈកម្មការក្រុងខ្មែរពាំនាំនូវការខកចិត្តរបស់លោកទៅជូនមន្ទីរផែនការក្រុង ដើម្បីជំរុញឱ្យសមត្ថកិច្ចក្រុងចាត់វិធានការចម្រេចការងារនេះឱ្យបានឆាប់ៗជៀសវាងការពន្យារពេលតទៅទៀត ។ គណៈកម្មការក្រុងខ្មែរក៏បានពាំនាំការបារម្ភរបស់លោកសមាជិកក្រុងប្រឹក្សាក្រុងទៅជូនថ្នាក់ដឹកនាំមន្ទីរផែនការក្រុងក្នុងអង្គប្រជុំនាថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៣ នៅឯមន្ទីរផែនការក្រុងឡូវែល ។ សាលាក្រុងបានសន្យាថា នឹងសម្រេចការដាក់ពង្រាយរចនាសម្ព័ន្ធរូបវន្តនីមួយៗតាមកាលបរិច្ឆេទដូចបានបញ្ជាក់ខាងដើម ។

ក្រៅពីការដាក់ពង្រាយរចនាសម្ព័ន្ធរូបវន្ត (Physical Structures) កំណត់សំគាល់ក្រុងខ្មែរ សាលាក្រុងក៏បានវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធ (Infrastructures) ដ៏សំខាន់មួយទៀត នៅក្នុងក្រុងខ្មែរឡូវែល ។ ជាក់ស្តែងសាលាក្រុងក៏បានចំណាយថវិការយ៉ាងហោចណាស់ចំនួន១៥0,000




Cambodia Town ~ Bench & Trash Styles ~ Jan 2012 ~ City of Lowell DPD

(១៥ម៉ឺនដុល្លារ) ដើម្បីដាក់ភ្លើងចាក់ដីបំពេញបង្កើតតារាងបាល់ទះ សាងសង់ បន្ទប់អនាម័យសាធារណៈសាងសង់តូបលក់ភេសជ្ជៈ និងដាំដើមឈើលើកម្ពស់សោភ័ណភាព ឧទ្យានសាធារណៈ Clemente Park ឬឧទ្យាន ប៉ៃលិនជូនដល់ប្រជាពលរដ្ឋខ្មែរអាមេរិកាំងគ្រប់រូបសំរាប់កំសាន្តកាយ និងអារម្មណ៍ ។ **តទៅទំព័រទី១៨**

# ១៨ មិនា ១៩៦៩ ជាដើមចមនៃវិបត្តិសុខភាពរបស់ពលរដ្ឋខ្មែរអាមេរិកាំង

**តពីលេខមុន**



សេងលី គួង

បណ្តាលមកពីការព្យាបាលសុខភាពផ្លូវកាយមិនបានរួមបញ្ចូលជាមួយនឹងការព្យាបាលសុខភាពផ្លូវចិត្ត ព្រោះថាសុខភាពផ្លូវកាយ និងផ្លូវចិត្តមានទំនាក់ទំនងគ្នាយ៉ាងជិតស្និត ហើយពលរដ្ឋខ្មែរអាមេរិកាំងដែលរស់រានពីរបប ប៉ុល ពត ភាគច្រើនមានជំងឺផ្លូវចិត្ត (មើលរូបទី ២: PTSD and Depression) ។ ចំណែកជំនាញការសុខភាពមួយភាគធំយល់ថា ការមិនជឿនលឿនផ្នែកសុខភាពគឺបណ្តាលមកពីការខ្វះខាតបុគ្គលិកបំរើការសុខភាពដែលនិយាយភាសាខ្មែរយល់ដឹងពីវប្បធម៌ទំនៀមទំលាប់ខ្មែរ និងពីប្រវត្តនៃអតីតជនភៀសខ្លួនខ្មែរ ។ ជាពិសេសការថយចុះទាំងចំនួនសមាគមខ្មែរ និងចំនួនបុគ្គលិកបំរើការនៅតាមបណ្តាសមាគមទាំងនោះគឺជាឧបសគ្គដ៏ចម្បងក្នុងការធ្វើឱ្យប្រសើរឡើងនូវសុខភាពខ្មែរអាមេរិកាំង។

ជាក់ស្តែងទន្ទឹមនឹងតំរូវការសេវាកម្មសង្គមកិច្ចរបស់ពលរដ្ឋខ្មែរកើនឡើងសមាគមខ្មែរដែលបំរើសេវាកម្មទាំងនេះប្រកបដោយប្រសិទ្ធិភាពខ្ពស់កំពុងថយចុះគួរឱ្យព្រួយបារម្ភណ៍ទៅវិញ។ មុនការកែទំរង់ប្រព័ន្ធសេវាកម្មសង្គមកិច្ចដោយរដ្ឋការលោកប្រធានាធិបតី Clinton ក្នុងទសវត្សឆ្នាំ១៩៩0សមាគមខ្មែរមាន១៥0អង្គភាពដែលផ្គត់ផ្គង់សេវាកម្មសង្គមកិច្ចដល់ជនភៀសខ្លួនខ្មែរនៅទូទាំងសហរដ្ឋអាមេរិក។ បច្ចុប្បន្ននេះសមាគមខ្មែរនៅសល់ប្រហែលតែ១០ អង្គភាពប៉ុណ្ណោះ ដែលនៅដំណើរ។ រីឯកម្មវិធីសង្គមកិច្ចដែលសមាគមធ្លាប់ដំណើរការដោយប្រសិទ្ធិភាពរួមមានកម្មវិធីបង្រៀនភាសាអង់គ្លេស ការបង្រៀន ទេព្យកោសល្យការងារ ការរកការងារជូនពលរដ្ឋខ្មែរ ការបំពេញបែបបទសុំរបបសង្គមកិច្ច ការសុំប័ណ្ណ សុខភាព កម្មវិធីការអប់រំសុខភាព កម្មវិធីបកប្រែភាសា និងកម្មវិធីផ្សព្វផ្សាយវប្បធម៌ ។ល។ ក៏បានសាបសូន្យដោយសារគ្មានថវិការគាំទ្រ។

សមាគមខ្មែរមានតួនាទីសំខាន់ក្នុងការផ្លាស់ប្តូរជាវិជ្ជមាននូវប្រព័ន្ធសេដ្ឋកិច្ច និងសង្គមកិច្ចដើម្បីទាមទារឱ្យប្រព័ន្ធសង្គមទាំងនេះឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងតំរូវការជាក់ស្តែងរបស់ពលរដ្ឋខ្មែរអាមេរិកាំង។ ឧទាហរណ៍សមាគមខ្មែរបានបង្រៀនអង្គភាពសង្គមកិច្ចអាមេរិកាំងនានាឱ្យយល់ដឹងអំពីទំនៀម ទំម្លាប់ ប្រពៃណី និងរបៀបរបបរស់នៅប្រចាំថ្ងៃរបស់ពលរដ្ឋខ្មែរអាមេរិកាំង។ សមាគមក៏បានបង្រៀន អង្គភាពទាំងនោះអំពីប្រវត្ត និងសោកនាដកម្មនានាដែលពលរដ្ឋខ្មែរបានឆ្លងកាត់ចាប់តាំងពីថ្ងៃចាប់ផ្តើមទម្លាក់គ្រាប់បែកជាសម្ងាត់នៅកម្ពុជា ១៨ មិនា ១៩៦៩ និងការធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ថ្ងៃទី ១៨ មិនា ១៩៧0 រហូតដល់របប ប៉ុល ពត និងជំរុំជនភៀសខ្លួននៅទល់ដែនថៃជាដើម។

មេដឹកនាំសមាគមយល់ថា ការយល់ដឹងផ្នែកវប្បធម៌ និងប្រវត្តិសោកនាដកម្មរបស់ពលរដ្ឋខ្មែរអាមេរិកាំងអាចជួយឱ្យអង្គភាពសេវាកម្មសាធារណៈទាំងនោះផ្តល់សេវាកម្មជូនខ្មែរកាន់តែមានប្រសិទ្ធិភាពខ្ពស់ថែមទៀត ។ ដូចយើងដឹងស្រាប់ហើយថាពលរដ្ឋអតីតជនភៀសខ្លួនខ្មែរភាគច្រើន (67%) មានជំងឺរន្ធត់ចិត្តដែលទាក់ទងជិតស្និតនឹងរោគផ្លូវកាយ។ ហេតុនេះការព្យាបាលរោគផ្លូវកាយអាចមានប្រសិទ្ធិភាពបាន លុះត្រាតែគ្រូពេទ្យស្វែងយល់ថា តើអ្នកជំងឺរបស់ខ្លួនអាចមានរោគរន្ធត់ចិត្តឬទេ ។ បើមានគេត្រូវតែព្យាបាលទាំងពីរមុខ ទើបអាចជាសះស្បើយបាន។ បើមិនអញ្ចឹងទេគេបានត្រឹមតែព្យាបាលរោគសញ្ញានៃជំងឺតែប៉ុណ្ណោះមិនបានព្យាបាលជំងឺនោះទេ។

ដើម្បីជួយស្រោចស្រង់សមាគមខ្មែរទាំងក្នុងមូលដ្ឋាន ក៏ដូចជានៅទូទាំងប្រទេសពលរដ្ឋខ្មែរអាមេរិកាំងគួរជួយគាំទ្រសមាគមខ្មែរឱ្យបានសកម្មថែមទៀតឱ្យដូចជាពលរដ្ឋចិនគាំទ្រសមាគមចិន វៀតណាមគាំទ្រសមាគមវៀតណាមដូច្នោះដែរ ។ បើមិនអញ្ចឹងទេ សមាគមខ្មែរនឹងត្រូវសាបសូន្យ ហើយពលរដ្ឋខ្មែរដែលត្រូវការសមាគមជួយក៏ត្រូវបាត់បង់ទីពឹងផ្អែកមួយភាគធំ។ ជាពិសេសការបាត់បង់សមាគមខ្មែរជាយថាហេតុណាមួយអាចជាការអាម៉ាស់មួយយ៉ាងធ្ងន់ធ្ងរដល់សហគមន៍ខ្មែរទាំងមូលថែមទៀតផង។

លោកអ្នកអាចគាំទ្រសមាគមខ្មែរដូចជាលោកអ្នកគាំទ្រវត្តអារ៉ាមអញ្ចឹងដែរ ដូចជាការជួយធ្វើទានជាថវិកាតាមលទ្ធភាព និងកាលវេលាដែលអាចធ្វើបាន។ តាមចំនួនប្រជាជនខ្មែរអាមេរិកាំងនៅឡូវែលចំនួនជាង៣0.000នាក់ បើម្នាក់ៗធ្វើទានដល់សមាគមតែ១០ដុល្លាក្នុងមួយឆ្នាំក៏បានចំនួន៣00.000ដុល្លា គ្រប់គ្រាន់សម្រាប់សមាគមបង្កើតមូលនិធិអាហារូបករណ៍ (Scholarship Fund) ដើម្បីជួយដល់និស្សិតដែលខ្វះខាតលុយកាក់ឱ្យបានទៅរៀននៅមហាវិទ្យាល័យ ឬបេឡាសង្គមកិច្ច (Social Fund) សំរាប់ជួយបុណ្យសពដល់ពលរដ្ឋខ្មែរ ជាពិសេសលោកតាលោកយាយដែលរស់នៅមណ្ឌលចាស់ជរា (Nursing Homes) ដែលស្លាប់ទៅគ្មានកូនចៅ ឬសាច់ញាតិ **តទៅទំព័រទី១៤**

# ខ្មែរអ្នកជាតិនិយម

តពីលេខមុន

បរិវេណអង្គរ, ខេត្តកំពង់ធំ និងខេត្តស្ទឹងត្រែង ។ នៅខែកក្កដា ឆ្នាំ១៩៤១នៅប្រទេសបារាំង ជប៉ុនបានធ្វើកិច្ចព្រមព្រៀងជាមួយបារាំងដែលបានអនុញ្ញាតឱ្យកងទ័ពជប៉ុនស្នាក់នៅនៅលើទឹកឥណ្ឌូចិនទាំងមូល។ ថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៤១ គឺមួយថ្ងៃក្រោយពីការវាយប្រហាររបស់ជប៉ុនទៅលើ Pearl Harbor កងយោធាជប៉ុនក៏បានចូលទៅប្រទេសសៀម តាមរយៈប្រទេសខ្មែរ។ ទោះបីជប៉ុនបានសន្យាថា នឹងគោរពអធិតេយ្យ និងបូរណភាពទឹកដីបារាំងនៅឥណ្ឌូចិននោះក៏ដោយរហូតមកដល់ខែមីនា ឆ្នាំ១៩៤៥ វត្តមាននៃកងទ័ពជប៉ុននៅឥណ្ឌូចិន បានជម្រុញពួកអ្នកជាតិនិយមនៅឥណ្ឌូចិនឱ្យហ៊ានចេញមុខធ្វើសកម្មភាពផ្សេងៗដើម្បីទាមទារឯករាជ្យរៀងៗខ្លួន។ ឯនៅប្រទេសយួនពួកអ្នកនយោបាយយួនក៏ឆ្លៀតឱកាសធ្វើការរំដោះជាតិពីខ្ញុំបារាំងផង ធ្វើនយោបាយពង្រីកទឹកដីផងដែរ។




### សកម្មភាពលោក សឺន ង៉ុកថាន់

នៅប្រទេសកម្ពុជា ស្នូរនៃចលនាតស៊ូអ្នកជាតិនិយម បានលេចឮឡើងតាំងពីក្រោយពេលដែលលោក **សឺន ង៉ុកថាន់** បានចូលមករស់នៅក្នុងក្រុងភ្នំពេញកាលពីឆ្នាំ១៩៣៥ ក្នុងរជ្ជកាលព្រះបាទ មុនីវង្ស ម៉្លេះ គឺមុនពេលជប៉ុនចូលមកប្រទេសខ្មែរទៅទៀត។

ក្រោយពីបានវិលត្រឡប់ពីការបំពេញវិជ្ជារបស់លោកនៅប្រទេសបារាំងនោះ លោក **សឺន ង៉ុកថាន់** បានព្យាយាមរកការធ្វើ ក្នុងរដ្ឋកាលអាណានិគមនិយមបារាំងនៅព្រៃនគរ តែរកពុំបានសោះ ព្រោះគេជ្រើសរើសយកតែជនជាតិយួន។ ដូច្នេះលោកក៏សម្រេចចិត្តមករកការងារធ្វើនៅក្រុងភ្នំពេញ ដោយបានទាក់ទងជាមួយលោក **ប៊ូ ហ៊ាង** ដែលជាប់ជាសាច់ញាតិនៃព្រះអង្គម្ចាស់ក្សត្រី ស៊ីសុវត្ថិ កុសុមៈ ជាព្រះមាតានៃទ្រង់សីហនុ។ អ្នកទាំងពីរបានខ្នះខ្នែងជួយលោក សឺន ង៉ុកថាន់ ឱ្យបានការធ្វើនៅក្រសួងយុត្តិធម៌មានឋានៈជាសុភាពចារបុរស ។ រួចមកលោកក៏បានជួបជាមួយមិត្តភ័ក្រ្តម្នាក់ជាជនជាតិបារាំងដែលធ្លាប់បានស្គាល់រាប់អានគ្នាកាលនៅប្រទេសបារាំងគេបាននាំលោកឱ្យធ្វើការជាមួយចាងហ្វាងនៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត គឺនៅទីនោះឯងហើយដែលលោកបានស្គាល់ ម៉ាច ឈឿន លោកគ្រូអាចារ្យ ហែម ចៀវ លោក នួន ដួង លោក ប៊ុណ្ណ ចន្ទម៉ុល ។ល។

ក្នុងរយៈពេលដែលលោកបានស្គាល់ជិតស្និទ្ធជាមួយអស់លោកទាំងនោះលោក សឺន ង៉ុកថាន់ ក៏បានធ្វើការទាក់ទងប្រមូលបញ្ញវ័ន្តក្មេងៗបានមួយក្រុមតូចដើម្បីរៀបចំគម្រោងការតស៊ូទាមទារយកឯករាជ្យពីបារាំង ។ ទាំងអស់គ្នាយល់ថាដើម្បីឱ្យសម្រេចកិច្ចការនេះ ជំហានដំបូង គឺត្រូវជ្រើសរើសយកព្រះរាជាមួយអង្គដែលមានវ័យក្មេង (យុវក្សត្រ)។ មានតម្រិះវិជ្ជា មានគំនិតទំនើប ដែលងាយស្រួលដល់ការណែនាំពន្យល់ពីកិច្ចការនយោបាយប្រទេសជាតិ ហើយជាអ្នកហ៊ានជួយចលនាតស៊ូទាមទារឯករាជ្យពីបារាំង ។ ទាំងអស់គ្នាក៏បានមូលមាត់សម្រេចចិត្តជាឯកច្ឆ័ន្ទថា នឹងត្រូវជ្រើសរើសយកស្តេចអង្គណាមួយដែលមានពូជឈាមជ័រជាក្សត្រទាំងពីរវង្សគឺ នរោត្តម និង ស៊ីសុវត្ថិ ។ បន្ទាប់ពីបានពិនិត្យខាងលើនេះហើយក៏បានព្រមព្រៀងគ្នាសម្រេចយកទ្រង់នរោត្តម សីហនុ កាលនោះ នៅក្មេងមានតម្រិះវិជ្ជា ហើយទ្រង់ក៏ជាព្រះរាជបុត្ររបស់ព្រះអង្គនរោត្តម សុរាម្រិត និងព្រះអង្គម្ចាស់ស្រ្តីស៊ីសុវត្ថិ កុសុមៈ ។ ម្យ៉ាងទៀតទាំងអស់គ្នាយល់ថា ព្រះអង្គម្ចាស់ស្រ្តីកុសុមៈដែលជារាជបុត្រីច្បងនៃព្រះបាទស៊ីសុវត្ថិមុនីវង្សពុំអាចស្នងរាជបានត្បិតទ្រង់ជាភេទស្រ្តីដែលច្បាប់ប្រពៃណីរាជបល្ល័ង្កខ្មែរមិនអនុញ្ញាតិឱ្យសោយរាជ្យ ។ អាស្រ័យហេតុនេះហើយបានជាចាប់ពីនេះមកគេសង្កេតឃើញក្រុមលោក សឺន ង៉ុកថាន់ តែងបានចុះជួបជុំគ្នានៅដំណាក់ព្រះអង្គម្ចាស់សុទ្ធារស និងដំណាក់ព្រះអង្គម្ចាស់សុរាម្រិត ។ ត្រង់នេះហើយដែលព្រះអង្គម្ចាស់ស្រ្តី កុសុមៈ ដែលជារាជមាតានៃនរោត្តមសីហនុមានព្រះទ័យសេចក្តីរីករាយជាងគេ ព្រោះបានកូនសោយរាជ្យជំនួស ហើយទ្រង់បានសន្យាជាមួយនឹងក្រុមលោក សឺន ង៉ុកថាន់ ថា ទ្រង់នឹងខំព្យាយាមគ្រប់មធ្យោបាយ ដើម្បីអប់រំកូនឱ្យទៅជាស្តេចមួយអង្គទ្រទ្រង់ទសពិធរាជធម៌ និងជួយគាំទ្រចលនាតស៊ូអ្នកជាតិនិយមទល់នឹងបារាំង ដើម្បីទាមទារយកឯករាជ្យ ។

ចំណែកឯក្រុមអ្នកជាតិនិយមវិញ ជាពិសេសគឺលោក សឺន ង៉ុកថាន់ ផ្ទាល់បានសន្យាអះអាងថា **តទៅលេខក្រោយ**







ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ច័ន្ទ ទី០៨ ខែកក្កដា ឆ្នាំ២០១៣

# លោក សម រង្ស៊ី សន្យាវិលមកកម្ពុជាវិញ នៅមុនពេលបោះឆ្នោត

**Colin Meyn និងបុប្ផា**

**ខេមបូឌា ដេលី**

លោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិដែលបានភៀសខ្លួនចេញពីប្រទេសកម្ពុជា ក្នុងឆ្នាំ២០០៩ មុនពេលត្រូវបានផ្តន្ទាទោសកំបាំងមុខដាក់លពន្ធនាគាររយៈពេល១១ឆ្នាំនោះ បាន សន្យាកាលពីថ្ងៃសៅរ៍ថា លោកនឹងវិលត្រឡប់មកប្រទេសកម្ពុជាវិញមុនការបោះឆ្នោតជាតិនៅថ្ងៃទី២៨ ខែកក្កដា ខាងមុខនេះ ។

មេដឹកនាំគណបក្សប្រឆាំងរូបនេះធ្លាប់បាន អះអាងថា ខ្លួននឹងវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ តែនៅពេលណាមានការលើកលែងបទចោទប្រកាន់លើរូបលោកដែលរួមមានទាំងបទញុះញង់បំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ និងផ្សព្វផ្សាយព័ត៌មានមិនពិត និងមានការអនុញ្ញាតឱ្យលោកចូលរួមដោយសេរីក្នុងការបោះឆ្នោតនាពេលខាងនេះប៉ុណ្ណោះ ។

លោក សម រង្ស៊ី មានប្រសាសន៍តាមរយៈវីដេអូមួយដែលត្រូវបានបង្ហោះលើទំព័រហ្វេសប៊ុករបស់លោកថា "ខ្ញុំមានកិត្តិយស និងក្តីសោមនស្សរីករាយសូមជូនដំណឹងប្រាប់ជនរួមជាតិកម្ពុជាជាទីនឹករលឹកថា ខ្ញុំនឹងត្រឡប់ទៅប្រទេសកម្ពុជាវិញ ។ ខ្ញុំនឹងទៅដល់មាតុភូមិវិញមុនការបោះឆ្នោតនៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១៣" ។

អង្គុយនៅទល់មុខទង់ជាតិកម្ពុជាក្បែរទង់គណបក្សសង្គ្រោះជាតិលោក សម រង្ស៊ី មិនបានប្រាប់ពីមូលហេតុដែលធ្វើឱ្យលោកហ៊ានត្រឡប់មកប្រទេសកម្ពុជាវិញទេ ។

លោក សម រង្ស៊ី បានមានប្រសាសន៍ថា "ខ្ញុំហ៊ានបូជាជីវិតរបស់ខ្ញុំ ដើម្បីបុព្វហេតុជាតិ ។ ខ្ញុំហ៊ានស្លាប់ដើម្បីសង្គ្រោះជាតិពីការបំផ្លិចបំផ្លាញ" ។

នៅពេលទាក់ទងកាលពីពេលម្សិលមិញ លោក សម រង្ស៊ី បានបដិសេធមិនផ្តល់សេចក្តីលម្អិតបន្ថែមថា តើលោកនឹងវិលត្រឡប់មកវិញនៅពេលណាឱ្យពិតប្រាកដ ថាតើលោកនឹងចូលក្នុងទឹកដីកម្ពុជាដោយវិធីណា ឬថាតើលោកបានឈានដល់កិច្ចព្រមព្រៀងណាមួយជាមួយរដ្ឋាភិបាលស្តីពីការវិលត្រឡប់មកវិញនេះ ឬយ៉ាងណាទេ ។

អាជ្ញាធរនៅក្នុងជួរកងកម្លាំងនគរបាលកម្ពុជាបានឱ្យដឹងកាលពីម្សិលមិញថា ប្រសិនបើលោក សម រង្ស៊ី វិលត្រឡប់មកវិញ ពួកគេមានភារកិច្ចអនុវត្តលើសេចក្តីសម្រេចៗរបស់តុលាការនោះ គឺការបញ្ជូនរូបលោកចូលធនាគារ ។

លោក គៀត ច័ន្ទថារិទ្ធ អ្នកនាំពាក្យនគរបាលជាតិបានមានប្រសាសន៍ថា "និយាយជាទូទៅនៅពេលឧក្រិដ្ឋជនឈានជើងចូលក្នុងប្រទេស ពួកគេត្រូវតែអនុវត្តទោសតាមសេចក្តីបង្គាប់របស់តុលាការ ។ ខ្ញុំគឺជាអ្នកអនុវត្តវច្បាប់ ដូច្នេះខ្ញុំមិនអាចនិយាយអ្វីឱ្យលើសនេះទេ" ។

ឧត្តមសេនីយ៍ឯក ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃបានឱ្យដឹងថា លោក សម រង្ស៊ី នឹងទទួលទោសតាមច្បាប់ដែលបានកំណត់ឱ្យលោកជាប់ពន្ធនាគាររយៈជាងមួយទសវត្សរ៍ ។

លោកបានមានប្រសាសន៍ថា "ខ្ញុំមិនអាចនិយាយចំៗទេ ប៉ុន្តែអ្នកត្រូវយល់ថា ប្រទេសកម្ពុជាស្ថិតនៅក្រោមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ហើយរាល់អនុក្រិត្យ ឬច្បាប់ គឺនៅតែស្ថិតនៅជាធរមាន" ។

ដើមឡើយលោក សម រង្ស៊ី ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលពីរឆ្នាំ កាលពីខែមករា ឆ្នាំ២០១០ ពីបទពាក់ព័ន្ធក្នុងការដកបង្គោលព្រំដែននៅតាមបណ្តោយព្រំដែនវៀតណាម ។ ក្នុងខែកញ្ញា ឆ្នាំ២០១០ លោកត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល១០ឆ្នាំ បន្ថែមទៀតពីបទក្លែងបន្លំឯកសារ និងផ្សព្វផ្សាយព័ត៌មានមិនពិតពាក់ព័ន្ធនឹងផែនទីដែលលោកបានបង្ហោះតាមប្រព័ន្ធអ៊ីនធើណេត ដើម្បីគាំទ្រអំណះអំណាងរបស់លោកដែលថា វៀតណាមបានទន្រ្ទានចូលទឹកដីកម្ពុជា ។ ក្រោយមកទោសជាប់ពន្ធនាគារសរុបរបស់លោក សម រង្ស៊ី ត្រូវបានសាលាឧទ្ធរណ៍បន្ថយមកនៅត្រឹមរយៈពេល១១ឆ្នាំ ។

ខណៈលោក សម រង្ស៊ី នៅតែបន្តប្រកាន់ជំហរចាស់របស់លោកថា បទចោទប្រកាន់លើរូបលោកមានហេតុផលនយោបាយនោះ លោក ផៃ ស៊ីផាន អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីបានលើកឡើងកាលពីម្សិលមិញថា រដ្ឋាភិបាលរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន គឺ"មិនប្រឆាំងនឹងលោក សម រង្ស៊ី ទាល់តែសោះ" ។

លោក ផៃ ស៊ីផាន បានមានប្រសាសន៍ថា "ដូចដែលសម្តេចនាយករដ្ឋមន្ត្រីបានលើកឡើងក្នុងវេទិកាសាធារណៈរួចមកហើយថា លោក សម រង្ស៊ី ខ្លួនឯងបានសម្រេចចិត្តចាកចេញដោយស្ម័គ្រចិត្ត ហើយមានតែគាត់ប៉ុណ្ណោះ ទើបអាចសម្រេចចិត្តថា តើត្រូវវិលត្រឡប់មកវិញ ឬអត់" ។

លោកបានបន្ថែមថា "រដ្ឋាភិបាលមិនប្រឆាំងនឹងលោក សម រង្ស៊ី សោះឡើយ ។ ប៉ុន្តែកាតព្វកិច្ចរបស់លោក សម រង្ស៊ី "ក្នុងការអនុវត្តទោសជាប់ពន្ធនាគាររបស់ខ្លួន" គឺជារឿងមួយផ្សេងទៀត មិនពាក់ព័ន្ធនឹងរដ្ឋាភិបាលទេ" ។

នេះមិនមែនជាលើកទី១ទេ ដែលលោក សម រង្ស៊ី បានសន្យាថា នឹងត្រឡប់មកប្រទេសកម្ពុជា

**តទៅទំព័រទី៧**

# SamRainsy Promises Return Before Election

**BY COLIN MEYNAND PHORN BOPHA**
**THE CAMBODIA DAILY**

Cambodia National RescueParty (CNRP) President SamRainsy, who fled the country in2009 prior to being sentenced inabsentia to 11 years in prison, on Saturday promised to return toCambodia before the nationalelection on July 28.The longtime opposition leader has previously said he would come back to Cambodia only if he was allowed to participate in a free and fair election process.

"I am honored and happy to tellmy much-missed, distinguishedfellow Cambodians that I will becoming back to Cambodia I willarrive in the motherland by election-day-July 28, 2013," Mr.Rainsy announced in a video postedto his Facebook page.

Seated in front of a Cambodianflag alongside a smaller flag bearingthe rising sun logo of theCNRP, Mr. Rainsy offered noqualifications for his return.

"I dare to sacrifice my life for the sake of the nation. I dare to die torescue the nation from destruction,"he said in the recording.

Contacted yesterday, Mr.Rainsy declined to give furtherdetails about when exactly hewould return or how he mightenter the country.

Authorities within Cambodia'spolice forces said yesterday that ifMr. Rainsy returns, they are obligedto implement previous decisions by the courts that would see the opposition leader placedbehind bars.

"Generally speaking, when Criminals enter the country, they have tobe sentenced in accordance withthe court," saidlieutenant GeneralKirthChantharith, spokesman for the national police. "I am a lawenforcer, so I cannot say morethan this," he added.

Lieutenant General KhieuSopheak, spokesman for theMinistry of Interior, said that Mr.Rainsywould be treated in accordancewith the same laws underwhich he was sentenced to morethan a decade in prison.

"I cannot speak directly, butyou need to understand that [the]state of Cambodia is under [the]Constitution of 1993, and everydecree or law under these conditionsstill remains," he said.

Mr. Rainsy was first handed atwo year prisonsentence in January2010 forcrimes related to the uprootingof demarcation pos1s alongthe Vietnamese border. In September 2010, he was sentenced to anadditional 10 years in prison forcrimes of forging publicdocuments and spreading disinformation in relationto maps he published on theInternet to support his claim that Vietnam has been encroaching on Cambodian land The totality of thesentence was later reducedby theAppeal Courtto 11 years.

While Mr. Rainsy has longheld that the charges against himwere politically motivated, PhaySiphan, spokesman for the Councilof Ministers, said yesterday that Prime Minister Hun Sen's government had "no oppositionto Sam Rainsy at all."

"As the prime minister already mentioned in a public forum, Sam Rainsy himself decided to leavevoluntarily, and only he can decideto come back," Mr. Siphansaid"The government has no opposition to Sam Rainsy at all. But Sam Rainsy's obligation [to servehis prison time] is another issuenot related to the government, "he added. **Continued on page 11**

# លោក ម៉ម សូណង់ដូ ប្រកាស គាំទ្រគណបក្សសង្គ្រោះជាតិពេញទំហឹងមុនការបោះឆ្នោត

**អួន ភាព**

**ខេមបូឌា ដេលី**

លោក ម៉ម សូណង់ដូ បានមានប្រសាសន៍ថា "ខ្ញុំគាំទ្រគណបក្សសង្គ្រោះជាតិស្របតាមសេចក្តីសម្រេចរួមរបស់សមាជិកខ្ញុំដែលព្រមព្រៀងគ្នាបោះឆ្នោតគាំទ្រគណបក្សនេះ" ។ លោកបានមានប្រសាសន៍ថា លោកមិនបានចូលរួមពាក់ព័ន្ធក្នុងយុទ្ធនាការឃោសនារបស់គណបក្សនយោបាយគណបក្សទេ ។

លោកបានមានប្រសាសន៍បន្តថា "គ្រាន់តែខ្ញុំគាំទ្រគណបក្សមួយមិនគាំទ្រគណបក្សមួយទៀតមិនមានន័យថា ខ្ញុំបានចូលរួមក្នុងឆាកនយោបាយទេ ។ ខ្ញុំនឹងនៅតែជាម្ចាស់ឯករាជ្យនៃស្ថានីយ៍វិទ្យុ និងសមាគមអ្នកប្រជាធិបតេយ្យរបស់ខ្ញុំមិនថា គណបក្សណាឈ្នះឆ្នោតនោះទេ " ។

លោក ម៉ម សូណង់ដូ បានបកស្រាយអំពីសេចក្តីសម្រេចរបស់លោក និងសមាគមលោកថា ជាភារកិច្ចអ្នកស្នេហាជាតិ ហើយលោកបានជំរុញឱ្យប្រជាពលរដ្ឋកម្ពុជាចូលរួមបោះឆ្នោតជាមួយលោក ដើម្បីគ្រប់គ្រងអំណាចរបស់គណបក្សប្រជាជនកម្ពុជា ប្រសិនបើមិនអាចបញ្ចប់ការកាន់អំណាចរបស់គណបក្សនេះបានទេនោះ ។

លោកបានមានប្រសាសន៍ថា "ខ្ញុំសូមអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ឱ្យគាំទ្រ "គណបក្សសង្គ្រោះជាតិ" ដើម្បីយើងកាត់បន្ថយអំណាចរបស់គណបក្សកាន់អំណាចបញ្ឈប់ការរំលោភបំពានសិទ្ធិមនុស្ស និងបញ្ចប់ការបណ្តេញចេញដោយសារការផ្តល់ដីសម្បទានយ៉ាងច្រើនឱ្យទៅក្រុមហ៊ុនវៀតណាម"៕

# ការប្រារព្ធខួបនៃការចុះប្រាសាទព្រះវិហារក្នុងបញ្ជីបតិកភណ្ឌពិភពលោកពាក់ព័ន្ធនឹងនយោបាយ

**ហ៊ុល រស្មី**

**ខេមបុឡា ដេលី**

ប្រជាពលរដ្ឋរាប់ពាន់នាក់មានទាំងនិស្សិត កម្មករ កម្មការិនីកាត់ដេរ ទាហាន និងមន្ត្រីរាជការ បាននាំគ្នាចូលទៅណែនណាន់តាន់តាប់ក្នុងបរិវេណពហុកីឡាដ្ឋានជាតិអូឡាំពិក កាលពីម្សិលមិញ ដើម្បីប្រារព្ធខួប៥ឆ្នាំនៃការចុះប្រាសាទព្រះវិហារក្នុងបញ្ជីបតិកភណ្ឌពិភពលោករបស់អង្គការសហប្រជាជាតិ ។

ដោយនៅតែប៉ុន្មានសប្តាហ៍ទៀតដល់ថ្ងៃបោះឆ្នោតជាតិនាថ្ងៃទី២៨ ខែកក្កដា នោះព្រឹត្តិការណ៍កាលពីម្សិលមិញនេះបានក្លាយជាឆាកនយោបាយដោយមានមន្ត្រីរដ្ឋាភិបាលឥតអៀនខ្មាសមួយចំនួនឆ្លៀតឱកាសនេះ ទាញយកការគាំទ្របន្ថែមទៀត សម្រាប់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ។

ដោយត្រូវបានចុះក្នុងបញ្ជីបតិកភណ្ឌពិភពលោកជាផ្លូវការកាលពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៨ ប្រាសាទសង់តាំងពីទសវត្សរ៍ទី១១ នេះបានក្លាយជាចំណុចក្តៅនាំឱ្យមានភាពតានតឹងជាមួយប្រទេសថៃក្បែរខាង ។ ហើយទោះបីជារដ្ឋាភិបាលក្រុងបាងកកបានបោះបង់ការទាមទារយកប្រាសាទនេះជាផ្លូវការនៅពេលតុលាការយុត្តិធម៌អន្តរជាតិបានប្រគល់ប្រាសាទព្រះវិហារមកឱ្យកម្ពុជាកាលពីឆ្នាំ១៩៦២ក្តីក៏ការចុះប្រាសាទព្រះវិហារក្នុងបញ្ជីបតិកភណ្ឌពិភពលោកកាលពីឆ្នាំ២០០៨ បានដុតកំហឹងអ្នកជាតិនិយមថៃឡើងវិញរហូតបង្កឱ្យមានការប៉ះទង្គិចគ្នាមួយប្រាវៗជាច្រើនលើកនៅតាមព្រំដែនបណ្តាលឱ្យមានអ្នកបាត់បង់ជីវិតចាប់តាំងពីពេលនោះមក ។

បច្ចុប្បន្នថៃ និងកម្ពុជាកំពុងតតាំងគ្នាជាថ្មីទៀតនៅឯតុលាការយុត្តិធម៌អន្តរជាតិពាក់ព័ន្ធនឹងដីទំហំ៤,៦គីឡូម៉ែត្រក្រឡានៅជាប់ប្រាសាទនេះ ។

មុនពេលបញ្ចប់ព្រឹត្តិការណ៍កាលពីម្សិលមិញលោកឧបនាយករដ្ឋមន្ត្រី សុខ អាន បានធ្វើយុទ្ធនាការគាំទ្រលោកនាយករដ្ឋមន្ត្រីតាមរយៈការលើកឡើងយ៉ាងពិសេស ។

លោក សុខ អាន បានមានប្រសាសន៍ថា "ជយោ! ព្រះរាជាណាចក្រកម្ពុជា ! ព្រះរាជាណាចក្រអច្ឆរិយៈក្រោមការដឹកនាំរបស់សម្តេចតេជោ ហ៊ុន សែន "។

លោក ប៉ា សុជាតិវង្ស អភិបាលរាជធានីភ្នំពេញ ទើបឡើងកាន់តំណែងថ្មី ដែលបាននិពន្ធចម្រៀងមួយបទលើសសរសើរប្រាសាទព្រះវិហារក្នុងព្រឹត្តិការណ៍នេះ ក៏បានកោតសរសើរលោកនាយករដ្ឋមន្ត្រីដែរ ។

លោក ប៉ា សុជាតិវង្ស បានមានប្រសាសន៍ថា "ខ្ញុំនឹងបន្តគាំទ្រសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដឹកនាំប្រទេសកម្ពុជា ដើម្បីការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សក្នុងអាណត្តិនេះ និងអាណត្តិបន្ទាប់ ។ ខ្ញុំសូមអបអរសាទរ និងសម្តែងការដឹងគុណសម្តេច ហ៊ុន សែន ចំពោះការដឹកនាំប្រទេសជាតិប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យដ៏ភ្លឺថ្លាក្នុងការការពារអធិបតេយ្យជាតិ"។

ក្នុងចំណោមមន្ត្រីដ៏ទៃទៀតដែលបានចូលរួមក្នុងព្រឹត្តិការណ៍កាលពីម្សិលមិញនេះដែរ រួមមានលោក ហ៊ុន ម៉ានី កូនប្រុសលោក ហ៊ុន សែន ដែលជាប្រធានចលនាយុវជនរបស់គណបក្សប្រជាជនកម្ពុជា និងជាបេក្ខជនតំណាងរាស្ត្រនៅមណ្ឌលខេត្តកំពង់ស្ពឺនៅការបោះឆ្នោតជាតិនាខែនេះផងដែរ ៕

*ប្រែសម្រួលដោយ ហម សុផាណ្ណា*

តមកពីទំព័រទី ១ សម រង្ស៊ី នឹងទៅដល់ប្រទេសកម្ពុជា...

នាយកគ.ជ.បក៏បានអនុញ្ញាតឱ្យមានការត្រួតពិនិត្យលើបញ្ជីឈ្មោះអ្នកបោះឆ្នោតដោយអង្គការឯករាជ្យ ហើយមានការប្រកាសរកឃើញការបាត់ឈ្មោះអ្នកបោះឆ្នោត



តមកពីទំព័រទី ៦ សម រង្ស៊ី សន្យាវិលមកកម្ពុជាវិញ...

បន្ទាប់ពីត្រូវបានផ្តន្ទាទោសក្រោមបទចោទប្រកាន់ដែលលោកអះអាងថា មានការលូកដៃពីលោក ហ៊ុន សែន ។

លោក សម រង្ស៊ី ក៏បានសម្រេចចិត្តចាកចេញពីប្រទេសកម្ពុជាអស់រយៈពេលជាងមួយឆ្នាំក្នុងឆ្នាំ២០០៥ ប្រឈមនឹងការចោទប្រកាន់ពីបទបរិហារកេរ្តិ៍លោក ហ៊ុន សែន និងអតីតប្រធានរដ្ឋសភាជាតិ និងគណបក្សហ៊្វុនស៊ិនប៉ិចគឺព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ។

ក្នុងខែវិច្ឆិកា ឆ្នាំ២០០៥ គឺបន្ទាប់ពីបាននិរទេសខ្លួនដោយខ្លួនឯងអស់រយៈពេលរាប់ខែ លោក សម រង្ស៊ី បានសន្យាវិលត្រឡប់មកមាតុភូមិវិញ"ក្នុងពេលឆាប់ៗ"។ នៅខែធ្នូក្នុងឆ្នាំដដែលនោះ លោកត្រូវបានផ្តន្ទាទោសកំបាំងមុខដាក់ពន្ធនាគាររយៈពេល១៨ខែ ពីបទបរិហារកេរ្តិ៍ ។ រយៈពេលបីខែក្រោយមកលោក សម រង្ស៊ី ត្រូវព្រះមហាក្សត្រនរោត្តមសីហនុព្រះរាជទានលើកលែងទោសបន្ទាប់ពីលោកបានសរសេរលិខិតសុំទោសជាសាធារណៈជូនចំពោះលោក ហ៊ុន សែន ផង និងព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ផង។

ទោះបីជាមានការអំពាវនាវជាច្រើនពីម្ចាស់ជំនួយអន្តរជាតិសុំឱ្យរដ្ឋាភិបាលអនុញ្ញាតឱ្យលោក សម រង្ស៊ី វិលមកចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតក្នុងខែកក្កដាក៏ដោយក៏ការអំពាវនាវនេះមិនបានទទួលផ្លែផ្កាមុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនេះឡើយ ។

នៅមុនខែកក្កដា ឆ្នាំ២០១២ លោក សុរិយា ស៊ូបេឌី អ្នកនាំពាក្យពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជាបានរាប់បញ្ចូលការវិលត្រឡប់របស់លោក សម រង្ស៊ី ទៅក្នុងបញ្ជីអនុសាសន៍ស្តីពីការធ្វើកំណែទម្រង់ដែលចាំបាច់សម្រាប់ការធ្វើឱ្យការបោះឆ្នោតមានលក្ខណៈសេរី និងយុត្តិធម៌ ។ ការអំពាវនាវស្រដៀងគ្នានេះត្រូវបានធ្វើឡើងដោយក្រសួងការបរទេសសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ។

នៅក្នុងខែមិថុនា លោក សម រង្ស៊ី ត្រូវបានរារាំងមិនឱ្យចូលក្នុងប្រទេសថៃដែលការសម្រេចនេះត្រូវក្រសួងការបរទេសថៃអះអាងថា ធ្វើឡើងដើម្បីទប់ស្កាត់លោក សម រង្ស៊ី ពីការ"ប្រើសកម្មភាពនយោបាយ ដើម្បីប្រឆាំងរដ្ឋាភិបាលកម្ពុជា" ។ លោក សម រង្ស៊ី បានអះអាងថា ការរារាំងលោកមិនឱ្យចូលប្រទេសថៃនេះ ធ្វើឡើងតាមសំណើររបស់រដ្ឋាភិបាល ហ៊ុន សែន ដែលបានច្រានចោលការអះអាងជាសាធារណៈ ។

ទោះជាយ៉ាងណាលោក ខាលីល ថេយើ (Carlyle Thayer) អ្នកនាំពាក្យតំបន់អាស៊ីអាគ្នេយ៍នៅសាលាបណ្ឌិតសភាកងកម្លាំងការពារជាតិអូស្ត្រាលី (Austalian Force Academy) បានលើកឡើងថា លោក សម រង្ស៊ី នឹងមិនជួបបញ្ហាអ្វីទេ ប្រសិនបើលោកព្យាយាមចូលទឹកដីកម្ពុជា ប៉ុន្តែការប្រកាសរបស់លោកនេះ គឺទំនងជាការប៉ុនប៉ងមួយទៀតក្នុងការបង្កើតសម្ពាធអន្តរជាតិលើលោក ហ៊ុន សែន ដើម្បីឱ្យលោកបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ។

លោកបានមានប្រសាសន៍ថា "ប្រសិនបើគាត់ "លោក សម រង្ស៊ី"ចង់វិលត្រឡប់មាតុប្រទេសវិញ លោកអាចធ្វើបាន ។ លោកគ្រាន់តែឡើងយន្តហោះ ហើយចូលមកក្នុងប្រទេសកម្ពុជាវិញជាការស្រេច ។ វាជាឆាកល្ខោននយោបាយដែលត្រូវបានរៀបចំឡើង ដើម្បីដកចេញនូវឧបសគ្គដែលរារាំងរូបលោកមិនឱ្យវិលត្រឡប់មកវិញ។ គាត់ "បានប្រកាសបែបនេះ" ដើម្បីឱ្យដឹងថា តើមានការដាក់សម្ពាធបែបណាខ្លះលើលោក ហ៊ុន សែន ដើម្បីឱ្យលោកអនុញ្ញាតឱ្យលោក សម រង្ស៊ី វិលត្រឡប់មកវិញ ៕

*ប្រែសម្រួលដោយ ភួន ច័ន្ទសេរីវុធ*

---

ប្រមាណ១០%ភាគរយ ដែលលទ្ធផលនេះនឹងមានការកែតម្រូវនៅពេលខាងមុខមុនពេលបោះឆ្នោត។

ដំណឹងទាំងពីរនេះ គឺជា"កាដូ"ដ៏រីករាយមួយដល់ពលរដ្ឋខ្មែរដែលនឹងឃើញការបោះឆ្នោតនៅកម្ពុជាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ខាងមុខនឹងទទួលផលគួរឱ្យពេញចិត្តជាងពេលមុនៗ ៕

**ខ្មែរផុសស.រ.អា**

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

៧៩៧.១៣០៧.៥៤១

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៣*

# មេធាវីថមាសស្ទីលីអាណូស

- ជួយធ្វើតាក់ដោយមិនបាច់មានលេខសូស្យាល់ (Filling Tax without Social Security)
- ជួយធ្វើគ្រីនកាត ១០ ឆ្នាំអោយបានបន្ទាប់ពីមានការលែងលះគ្នា (Divorced 10 year Green Card)
- ជួយធ្វើគ្រីនកាត ២ ឬ ១០ឆ្នាំ (Help with 2 or 10 year Green Card)
- ជួយអ្នកដែលនៅលើសកំណត់អោយបាននៅក្នុងប្រទេសបន្តទៀត (Help Overstay Bars)
- ជួយការពារកុំអោយគេបញ្ជូនទៅស្រុកវិញបន្ទាប់ពីបានប្រព្រឹត្តិខុសច្បាប់ (Criminal Deportation)
- ជួយរៀបចំឯកសារធានាឪពុកម្តាយកូននិងបងប្អូនមកអាមេរិច (Get Parents, Children and Sibling Here)
- ជួយរៀបចំឯកសារសំរាប់ធានាប្តីប្រពន្ធ ឬគូរដណ្តឹងមកអាមេរិច (Get Spouse or Fiancé Here)
- ជួយរៀបចំឯកសារសុំលែងលះប្តីប្រពន្ធ (Divorce, only in Massachusetts)
- ជួយការពារ និងធ្វើជាតំណាងក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍ (Car Accident, only in Massachusetts)
- ជួយធ្វើការតវ៉ានៅចំពោះមុខក្រុមប្រឹក្សាសាលាឧទ្ធរណ៍ផ្នែកអន្តោប្រវេសន៍ (BIA Immigration Appeals)
- ជួយធ្វើឯកសារចូលសញ្ជាតិដល់សាមុីខ្លួន និងកូនៗរបស់លោកអ្នក (N-400 and N-600)
- ជួយធ្វើគ្រីនកាតថ្មីបន្ទាប់ពីត្រូវគេលួច ឬបាត់បង់ (I-90, Replacement Green Card)
- ជួយសុំកាតធ្វើការ (Work Card)
- ជួយធ្វើលិខិតធ្វើដំណើរចេញចូល (Re-entry Permit)

# Thomas Stylianos Law Offie

## 287 Appleton Street, Suit 205 Lowell, MA 01852

# Tel: 978-459-5000

## E-mail: Tom@stylianoslaw.com

Attorneys' only licensed in Massachusetts

# សេចក្តីអញ្ជើញ

គណៈកម្មការ **ក្លេមិនតេផាក** គណៈកម្មការភូមិខ្មែរ ព្រមទាំងគណៈកម្មការគាំទ្របេក្ខភាព លោក នួន វាសនា មានកិត្តិយស សូមអញ្ជើញលោក លោកស្រីអ្នកនាងកញ្ញាប្រិយមិត្ត រួមជាភ្ញៀវកត្តិយសក្នុងពិធីជប់លៀង ពិសារភោជនាហារតាមកម្មវិធីខាងក្រោមនេះ

**ថ្ងៃសៅរ៍ ទី ១៣ កក្កដា ២០១៣**
**ម៉ោង ៦ ល្ងាច ដល់ ម៉ោង ១២ អាធ្រាត**
ភោជនីយដ្ឋាន **សំពៅមាស**

**វិភាគទាន**: ២៥ ដុល្លា ក្នុងមនុស្ស ម្នាក់។

ព័ត៌មានបន្ថែមទៀត សូមទាក់ទងទៅ អ្នកស្ម័គ្រចិត្តមាននាមក្នុងសំបុត្រអញ្ជើញនេះ។ **សូមអរគុណ!**

Clemente Park Committee, Cambodia Town Committee, and the Committee to re-elect Vesna Nuon have the honor to invite you to attend a dinner reception at a fundraising in honor of Vesna Nuon Lowell City Council



**Saturday, July 13, 2013**
**6:00 pm to Midnight**
**Sompov Meas** Restaurant
450 Chelmsford St. Lowell, MA 01851

- Four course dinner and soft drink
- Cash Bar
- Dancing with live band

Suggested Donation: $25 per person

**For more information:**
Sambath Bo: **(978) 399-8039** /Sengly Kong: **(978) 364-1911**
Rithy Uong **(978) 996-6969** / Paul Ratha Yem **(617) 459-3000**

# ភោជនីយដ្ឋាន សុភមង្គលថ្មី

"New Happiness Restaurant"
Open from 7:30AM-9:00PM




**ទើបបើកថ្មីនៅឡូវែល**
**ម្ចាស់ថ្មី, ហាងខ្មែរ, ម្ហូបខ្មែរពិត។**




**ម្ហូបដែលភ្ញៀវតែងចូលចិត្តពិសារ**

**ពេលព្រឹក :** គុយទាវ $5.95
**ម្ហូបពិសេស :** មីទាផាកឡូវ Meetea phaklov $7.95
**ពេលថ្ងៃ និងល្ងាច:** សម្លកកូរ , សម្លម្ជូរគ្រឿង,សម្លម្ជូរសៀមរាប, $11.95
គ្រឿងសមុទ្រផ្សិតស្រួយ, ពោះវៀនខស្តេជូ,
សម្លរផ្កាំងភ្លើង,គ្រឿងក្លែមសាមគ្គី

*និងមានម្ហូបច្រើនមុខទៀត ធ្វើដោយចុងភៅល្បីឈ្មោះ ដែលមានជំនាញជាង៣០ឆ្នាំហើយ នៅភ្នំពេញ និងសៀមរាប*


Som-law Ka kor


Cha knyei · Som-law ma-ju tro koun · Mee Ka Tang · Roasted pork

អាស័យដ្ឋាន: 6 Branch Street Lowell. MA 01851
ទូរស័ព្ទ : **(978)454-4727**

## កម្មវិធីថែសុខភាពតាមគេហដ្ឋានសម្រាប់ចាស់ៗ និងជនពិការភាព

- នាងថែខ្ញុំដូចជាម្តាយបង្កើត ខ្ញុំសប្បាយចិត្តណាស់
- នាងស្រឡាញ់និងថែខ្ញុំដូចជីដូនបង្កើត
- នាងចំអិនម្ហូប បោសសំអាតផ្ទះ បោកខោអាវ ហើយស្តាប់រឿងខ្ញុំពេលខ្ញុំកើតទុក្ខ
- ខ្ញុំមានពេទ្យមកពិនិត្យសុខភាពជាប្រចាំ
- នាងរលឹកពេលដែលខ្ញុំត្រូវញាំថ្នាំ គ្រប់ពេលវេលា
- នាងជូនខ្ញុំដើរលេងលំហែកាយ
- នាងជួយខ្ញុំទិញម្ហូបនិងសំភារៈប្រើប្រាស់
- កូនខ្ញុំមិនព្រួយអំពីភាពអត់ការងារធ្វើ ហើយបាននៅក្បែរខ្ញុំគ្រប់ពេលវេលា
- ព្រឹទ្ធាចារ្យជាដុំពេជ្យក្នុងសង្គមយើង ចូរអ្នកទាំងអស់ខំថែទាំគាត់អោយមានអាយុវែងនិងសុខភាពល្អ។

ក្រុមហ៊ុនយើងខ្ញុំកំពុងជ្រើសរើសបុគ្គលិកធ្វើការ
សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធីនេះសូមទាក់ទង

ម៉ូនីដា (២៦៧) ២៦២-៣៩២៩ ដេវីដ (២៦៧) ៩១៨-៨៤៩៣

HOME CARE
**Aurora**



LOWELL ELDER CARE
978-596-1111

# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

345 Chelmsford St. Lowell, MA 01851/ – www.lowelleldercare.com

## អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ្ឋានកក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

## ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។



## មណ្ឌលផ្តល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

## Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips

**សូមហៅលេខទូរស័ព្ទ (978) 596-1111**



Simply Khmer

# ភោជនីយដ្ឋានស៊ីម ភ្លីខ្មែរ

Simply Khmer Restaurant



Open 7 days a week from 8AM-9PM

បើករៀងរាល់ថ្ងៃ ចាប់ពីម៉ោង៨ព្រឹក ដល់ម៉ោង ៩យប់

26 Lincoln #4, Lowell, MA 01851 • (978) 454-6700

គេហទំព័រ: www.simplykhmerrestaurant.com



SIM'S Home Improvement

Major Sim Enterprises, Inc.

# ជាងសំណង់តាស៊ីម




Repairing •Remodeling •Additions

ជួសជុល កែលំអរ សង់បន្ថែម

| | | | |
|---|---|---|---|
| Kitchen | ចង្ក្រានបាយ | Siding | ជញ្ជាំង |
| Livingroom | បន្ទប់ទទួលភ្ញៀវ | Window | បង្អួច |
| Bathroom | បន្ទប់ទឹក | Door | ទ្វារ |
| Bedroom | បន្ទប់ដេក | Basement | ជាន់នៅក្រោមដី |
| Roofing | ដំបូល | Additions | បន្ទប់បន្ថែម |

Residential • Commercial • Industrial

ទទួលប្រាក់គ្រប់ប្រភេទ

Bank Loan, Insurance, Compensation, Credit Debit, Check &Cash

More information call: 1.978.452.7467

www.SimsHomeImprovement.com
Boreth@SimsHomeImprovement.com

## Rainsy ...

CONTINUED FROM PAGE 6

This is not the first time that Mr.Rainsy has promised to return tothe countryafter being sentenced overcharges he claimed Mr. Hun Sen had a hand in.

Mr. Rainsy also decided to leave the country fur more than a year in 2005 facing charges that he had defamed Mr. Hun Sen and then National Assembly and Funcinpec President Prince Noradom Ranariddh.

In November 2005, after month sin self-imposed exile, Mr. Rainsy promised to return to the country" in the near future." In Decemberof that year, he was sentenced inabsentia to 18 months in prison for defamation. 1hree months later, Mr. Rainsy was pardonedby King Norodom Sihamoniafter writing public letters of apology to both Mr.Hun Senand Prince Ranariddh.

Despite numerous calls frominterna-tional donors for the governmentto allow Mr. Rainsy'sreturn to contest July's poll, nosuch political bargain has beenstruck in the lead-up to this year'sparliamentary election.

In July 2012, Surya Subedi, the U.N.'s special rapporteur for human rights in Cambodia, included Mr. Rainsy's return among alitany of reforms necessary to ensure free and fair elections.Similar calls have been made bythe U.S. State Department and theEuropean Union.

In June, Mr. Rainsy was blocked from entering Thailand,a decision that the Thai Foreign Ministry said was made to preventhim from "manipulat[ing] political activities against the governmentof Cambodia." Mr.Rainsy claimed that the denial ofhis entry was done at the behestof the administration of Mr. Hun Sen, a claim that the prime ministerpublicly denied.










# ពេទ្យធ្មេញសំរាប់គ្រួសារ

## Caring Dental For ALL Ages




**FREE**
Teeth Whitening
New patients get a complimentary teeth whitening kit with completed exam, cleaning & x-rays at regular price. Cannot be combined with any other offers. Expires 07/27/13

"EXCLUSIVE OFFER"
$55.00
Limited Time New Patient Special
(Regular Discount $55.99 a $250 Value)
Present coupon for discount. Includes exam, bite-wing x-ray & cleaning. Cannot be combined with other offers or insurance. Expires 07/27/13

### COMPLETE ផ្តល់គ្រប់សេវាកម្ម Services

- Cosmetic Dentistry
- Cosmetic Fillings
- Crowns & Bridges
- Dentures
- Extractions
- Implant Crowns
- Root Canal Therapy

- ត្រួតពិនិត្យទៀតទាត់ពេល
- សំអាតធ្មេញ
- ជំងឺចព្រាញធ្មេញ
- ដកសរសៃធ្មេញ
- ស្រោប-តម្រឹម និងប៉ះធ្មេញ
- ធ្វើធ្មេញឱ្យស
- បំពេញធ្មេញប្រហោង
- ដកធ្មេញ

### Convenient LOCATION

Next to Bank of America on Chelmsford Street




Most Forms of Insurance & Payment
ACCEPTED ទទួលគ្រប់ អ៊ិនស្វ៊ិរិន
MassHealth • Cigna • Aetna
Amex • Discover • Visa • Mastercard

យើងមានអ្នកនិយាយភាសាខ្មែរ អង់គ្លេស ស្បានីស និងវៀតណាម សូមទូរស័ព្ទ 978-455-4039 ដើម្បីណាត់ជួបនាថ្ងៃនេះ

724 Chelmsford Street • Lowell, MA • 978-455-4039
www.BrightSmiles–Dental.com



# Lowell Community Health Center

161 Jackson Street, Lowell, MA 01852

## Caring for Lowell

Lowell Community Health Center provides professional health care services to the people of Greater Lowell. The Health Center's caring staff speak Khmer and many other languages. We accept all forms of health insurance, and we can help you apply for insurance coverage for your medical care. Services include:

- Doctor's Visits
- Behavioral Health Counseling
- Social Services
- Traditional healing, acupuncture, massage therapy

LOWELL COMMUNITY HEALTH CENTER

Accepting New Patients

Services in English & Khmer

មណ្ឌលសុខភាពសហគមន៍ក្រុងឡូវែលផ្តល់ជូននូវសេវាសុខភាពដោយអ្នកមានជំនាញច្បាស់លាស់ទៅដល់ប្រជាជនទូទៅដែលរស់នៅក្នុងតំបន់ឡូវែល ។ យើងមានបុគ្គលិកថែទាំសុខភាព ដែលនិយាយភាសាខ្មែរ និងភាសាផ្សេងៗទៀត ។ យើងក៏អាចជួយលោកអ្នក ក្នុងការដាក់ពាក្យសុំការធានាសុខភាព សម្រាប់សេវាថែទាំសុខភាពលោកអ្នកផងដែរ ។ សេវាថែទាំសុខភាពរួមមាន :

- ការពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិត
- ការប្រឹក្សាអំពីសុខភាពផ្នែកអារម្មណ៍ និងផ្លូវចិត្ត
- សេវាសង្គម
- ការព្យាបាលបែបបុរាណ បែបចាក់ម្ជុលវិទ្យាសាស្រ្ត បែបម៉ាសាធ្វើសរសៃ



Join Our Team. Now Hiring!

## Work at Lowell Community Health Center

The Health Center offers rewarding career opportunities to medical and behavioral health professionals and support staff. Visit our website to learn more about joining our diverse team.

មណ្ឌលសុខភាពកំពុងផ្តល់ឱកាសដល់ពេទ្យផ្នែកព្យាបាល ពេទ្យជំនាញផ្នែកអារម្មណ៍ និងផ្លូវចិត្ត និងបុគ្គលិកថែទាំសុខភាព ។ សូមចូលទៅកាន់គេហទំព័រ www.lchealth.org ដើម្បីស្វែងយល់ពីរបៀបចូលរួមជាមួយក្រុមដែលមានលក្ខណៈសំបូរបែបនេះ ។

978-221-6777
www.lchealth.org



# ONEWORLD PHARMACY

Expect Excellence

# ឱសថស្ថានខ្មែរ

នៅក្រុងឡូវែល ដំបូងបង្អស់

First Khmer Pharmacy in Lowell
12 years as a retail drug store pharmacist



Soriya Sok, R. Ph. (Owner)

### សួស្តី!ឱសថស្ថានខ្មែរនៅឡូវែល

- យើងយកថ្នាំជូនដល់ផ្ទះ
- ឱសថការី និយាយនិងសរសេរខ្មែរ
- ពិគ្រោះពីថ្នាំដែលពេទ្យចេញឲ្យ
- អាចស្នើឲ្យចែកថ្នាំ តាមពេលប្រើ
- អាចស្នើឲ្យកាត់ថ្នាំគ្រាប់ជាភាគតូចៗ
- ទទួលយកអ៊ិនស្វូរិន ស្ទើរគ្រប់ធុន
- ប្តូរកន្លែងបើកថ្នាំជូនបាន




Hours of Operation
Monday-Friday: 9AM-7PM
Saturday: 9AM-4PM
Closed Sunday

One World Rx
HealthMart Pharmacy
www.pneworldpharmacy.org

Health Mart PHARMACY
គ្រូពេទ្យអាចបញ្ជាឲ្យទិញថ្នាំតាមទូរស័ព្ទ ហ្វាក់ និង E-script បាន

138 Highland Ave., Unit 5
Lowell, MA 01851

Tel: 978-455-4066 Fax: 978-455-1578




# សាលា( Lowell Day Nursery )
## ពីថ្នាក់ដំបូងរហូតដល់ថ្នាក់មត្តេយ្យ




▸ សាលាជាទីកន្លែងលោកអ្នកឮសំលេងកូនក្មេងសើចសប្បាយរីករាយ និងឃើញកូនក្មេងក្រេបជញ្ជក់នូវចំណេះដឹងបានល្អ ។

▸ សាលា(Lowell Day Nursery) បានជួយកូនក្មេង និងក្រុមគ្រួសារតំបន់ឡូវែលបានជាង១០០ឆ្នាំងមកហើយ។

ដូច្នេះពួកគចង់ជួយលោកអ្នក និងក្រុមគ្រួសាររបស់អ្នកផងដែរ។

▸ ទទួលចុះឈ្មោះចាប់ពីកូនក្មេងអាយុ១៥ខែ រហូតដល់មត្តេយ្យ ចំពោះក្រុមគ្រួសារដែលមានប្រាក់ចំណូលទាបសាលា ក៏ប្រហែលមានមួយចំនួនសំរាប់ដល់ពួកគេដែរ ហើយចំពោះក្រុមគ្រួសារដែលមានប័ណ្ណគណនេយ្យ (Vouchers) ក៏សាលាចុះឈ្មោះដែរ ។

តម្លៃការសិក្សានៅសាលា(Lowell Day Nursery) មានកំរិតទាបជាងគេបំផុតក្នុងសាលាផ្សេងៗនៅក្នុងទីក្រុង Lowell។

▸ ដើម្បីធ្វើការណាត់ជួបក្នុងការទស្សនកិច្ចបរិវេណសាលាព្រមទាំងជួបជាមួយបុគ្គលិក សូមទាក់ទង តាមទូរស័ព្ទលេខ : (978)454 5981 ឬតាមអាស័យដ្ឋានលេខ ១១៩ ផ្លូវ Hall, Lowell MA ០១៨៥៤

# ផ្សារអាត្លង់ទីក

**Atlantic Market**

135 main St, Danbury, CT 06810

**203-830-3068**




ផ្សារនេះមានម្ចាស់ឈ្មោះ **ដាន់ ស៊ីខ** បើកលក់ដូរតាំងពី១០ឆ្នាំមកហើយ ជាពិសេសយើងជាអ្នកលក់ត្រីស្រស់ៗនៅក្នុងក្រុង ។ បន្ថែមពីលើលក់ត្រីស្រស់ យើងមានលក់បន្លែសម្រាប់ម្ហូបអាស៊ី ។

**យើងទទួលយក :** American Express -លុយសុទ្ធ -Debit card -Master Card -Visa

**បើកទ្វារ :** ថ្ងៃច័ន្ទ ម៉ោង ៩:៣០ព្រឹក ដល់៧ល្ងាច/ ថ្ងៃអង្គារ៍ ដល់ថ្ងៃសៅរ៍ ៩:៣០ដល់៨ល្ងាច/ ថ្ងៃអាទិត្យ ៩:៣០-៧:០០




**ទីផ្សារតថយន្តឥតគិតថ្លៃ**



# ខ្មែរផុសស្វាគមន៍គ្រួសារខ្មែរដែលប្រឹងប្រែងបណ្តុះអនាគតកូនចៅខ្លួន

ខ្មែរផុសធ្លាប់បានសន្យាថា នឹងខំរកមធ្យោបាយធ្វើឱ្យក្មួយប្រុសស្រីទាំងដែលជាកូនចៅរបស់អស់លោកអ្នកបានខំប្រឹងប្រែងសិក្សាមានស្នាដៃពិសេសនៅសាលា, នៅវិទ្យាល័យ,នៅសាកលវិទ្យាល័យទាំងឡាយបានសប្បាយរីករាយ,មានមោទនភាព, ក្លាហានបោះជំហ៊ានទៅមុខទៀតដើម្បីដណ្តើមយកកិត្តិយសមកឱ្យខ្លួនឯងគ្រួសារខ្លួននិងសហគមន៍ខ្មែររបស់ខ្លួន ។

យើងបានជួបសម្ភាសន៍ជាមួយក្មួយបេណៃត គីម និងក្មួយស្រី គីម ច័ន្ទទេវី ជាឪពុក និងម្តាយនៃកូនស្រីពីរនាក់, កូនស្រីទី១ឈ្មោះ Adelaide Kim អាយុ១១ឆ្នាំ បានប្រឡងចេញជាប់យ៉ាងជោគជ័យពីបឋមសិក្សា Fax Chase នៅក្រៅក្រុងហ្វីឡាដែលហ្វៀ ហើយបានចូលទៅរៀននៅអនុវិទ្យាល័យបុលឌីតាមដងវិថីវែដឡាយិន-ផ្នែកខាងជើង និងខាងកើតទីក្រុងហ្វីឡា ។ កូនស្រីទី២តូចច្រឡឹងអាយុទើបបាន៩ឆ្នាំមិនទាន់បានចូលមត្តេយ្យសាលាទេ តែចេះប្រកបបានយ៉ាងងាយដោយសារមើលកម្មវិធីទូរទស្សន៍ និងឡែបថប់តែម្នាក់ឯងក្បែរលោកតារបស់នាង គឺលោកតាគីមភៀន អ្នកនិពន្ធរឿងស្នេហាលន្លង់លន្លោច,



**ព័ត៌មានជំនួយ :**

-អាដែលឡែដ អាយុ១១ឆ្នាំ

-ប្រលងចេញជាប់ដោយជោគជ័យ, បានទទួលការកោតសរសើរពីលោកប្រធានាធិបតី អូបាម៉ា

-ជ្រើសរើសសិស្សអានសៀវភៅល្អនៅវិមានកាពីតូល, បានជាប់លេខមួយក្នុងចំណោមសិស្សទាំងអស់នៅស្រុកហ្វីឡា Philadelphia Country

-បានសាលានាំរៀននាំនាងដើរលេងតាមបាល់ទេសចរគ្រួស

## តមកនំព័រទី ៣ ១៨ មិថុនា ១៩៦៩...

ជួយធ្វើបុណ្យសពជូនតាមប្រពៃណីខ្មែរ ឬជួយដោះទ័លមួយគ្រាជូនបងប្អូនដែលមានគ្រោះអាសន្នភ្លើងឆេះផ្ទះជាដើម។ ទាំងនេះ គឺសុទ្ធតែជាបុណ្យកុសល្យដែលលោកអ្នកទទួលបានមិនខុសពីបុណ្យទានដែលធ្វើនៅវត្តនោះទេ។ វត្តអារាមក៏អាចបង្កើតមូលនិធិអាហារូបករណ៏ (Scholarship Fund) សំរាប់ឧបត្ថម្ភដល់និស្សិតខ្មែរអាមេរិកាំងទៅរៀននៅមហាវិទ្យាល័យផងដែរ។ វត្តអារាមខ្មែរជាទូទៅបានទទួលជោគជ័យណាស់ក្នុងការប្រមូលបច្ច័យ។ ខ្ញុំឮថា មានពេលខ្លះ វត្តអាចប្រមូលបច្ច័យបានរាប់សែនដុល្លាក្នុងពេលបុណ្យធំៗម្តងៗ រហូតដល់រាប់រយៈពេល៣ទៅ៤ថ្ងៃទើបចប់។ ខ្ញុំគិតថា បើវត្តបង្វែបច្ច័យមួយភាគសំរាប់បង្កើតមូលនិធិអាហារូបករណ៏សំរាប់ជួយដល់និស្សិតខ្មែរនោះវត្តអារាម ក៏ដូចជាពុទ្ធបរិស័ទរបស់យើងមិនត្រឹមតែបានជួយអភិវឌ្ឍន៏វិស័យព្រះពុទ្ធសាសនាខ្មែរប៉ុណ្ណោះទេ តែយើងបានជួយកសាងសមត្ថភាពកូនខ្មែរជំនាន់ក្រោយ ហើយនិស្សិតទាំងនេះនឹងត្រលប់មកជួយសហគមន៏ខ្មែរក៏ដូចជាវត្តអារ៉ាមរបស់យើងវិញក្រោយពេលពួកគេបានបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ។ នេះគឺជាយុទ្ធសាស្រ្តឈ្នះ-ឈ្នះនៃសហគមន៏ខ្មែរអាមេរិកាំងយើង។

ក្រៅពីនេះលោកអ្នកអាចជួយសមាគមខ្មែររបស់យើងដោយជួយនិយាយពាក្យល្អៗអំពីសារៈសំខាន់របស់សមាគមប្រាប់ដល់អ្នកនយោបាយសមាជិកសភា ឬព្រឹទ្ធសភាអាមេរិកាំងដែលលោកអ្នកស្គាល់ ដើម្បីសុំឱ្យគេជួយផ្គត់ផ្គង់ថវិការដល់សមាគមខ្មែរឱ្យដូចដែលគេជួយគាំទ្រសមាគមអា-មេរិកាំងដ៏ទៃទៀតដែរ។

លោកអ្នកអាចរំលឹកមិត្តភ័ក្រ្តអាមេរិកាំងដូចអ្វីដែលមេដឹកនាំសហ-គមន៏ខ្មែរអាមេរិកាំងម្នាក់ធ្លាប់បានរំលឹកអ្នកដឹកនាំអាមេរិកាំងថា "ពលរដ្ឋអាមេរិកាំងមិនគួរភ្លេចថា យើងជាសម្ព័ន្ធភាពរបស់គេ ហើយមូលហេតុតែមួយគត់នៃការទម្លាក់គ្រាប់បែកដែលបានសម្លាប់មនុស្សយ៉ាងហោចណាស់ ៥០០.០០០(៥០ម៉ឺន)នាក់ គឺដើម្បីការពារសុវត្ថិភាពនៃការដកទ័ពអា-មេរិកាំងចេញពីឥណ្ឌូចិន។ ពលរដ្ឋអាមេរិកាំងមិនគួរភ្លេចថា រដ្ឋាភិបាលអាមេរិកាំងបានយល់យ៉ាងច្បាស់នូវអ្វីដែលបានកើតឡើងចំពោះយើងក្នុងសម័យ ប៉ុល ពត ព្រមទាំងបានបិទភ្នែកធ្វើមិនឃើញចំពោះការឈឺចាប់របស់យើង។ ពលរដ្ឋអាមេរិកាំងមិនគួរភ្លេចថា រដ្ឋាភិបាលអាមេរិកាំងបានគាំទ្រខ្មែរក្រហមថា ជារដ្ឋាភិបាលស្របច្បាប់របស់កម្ពុជា ថ្វីត្បិតគេបានដឹងជាយូរមកហើយនូវទំហំនៃការរំលោភសិទ្ធមនុស្សរបស់ពួកនេះ ។ ជាពិសេសពលរដ្ឋអាមេរិកាំងបានដឹងយ៉ាងច្បាស់ថា នៅពេលដែលគេអនុញ្ញាត្តិឱ្យយើងមករស់នៅសហរដ្ឋអាមេរិក យើងមានសេចក្តីត្រូវការពិសេសតែគេបែរជាធ្វើមិនដឹងមិនឮចំពោះតំរូវការពិសេសរបស់យើង"។ ករណីនេះត្រូវបានទទួលស្គាល់ដោយ Lavinia Limón ប្រធានការិយាល័យជនភៀសខ្លួនអាមេរិកក្នុងបទសម្ភាសន៏មួយជាមួយកាសែត New York Time ក្នុងឆ្នាំ២០០៣ថា "កម្មវិធីជនភៀសខ្លួនកម្ពុជាជាមហាបរាជ័យមួយនៃនយោបាយជនភៀសខ្លួននៅក្នុងប្រទេសអាមេរិក។ កំហុសទី១ គឺយើងមិនបានចាត់ទុកជនភៀសខ្លួនកម្ពុជា ជាករណីដោយឡែកមួយដែលខុសពីជនភៀសខ្លួនដ៏ទៃទៀត៕




# វិស្វកម្មក្នុងចិត្តមនុស្ស
## The human inner engineering

**តពីលេខមុន**



និពន្ធដោយ : ម៉ៅ ច័ន្ទសំណុំ

៣-ចំណុចមួយដែលលេចធ្លោ ហើយគួរឱ្យចាប់អារម្មណ៍បំផុតនោះ គឺអាទិភាពនៃសតិដឹងនិងម៉េម័រី ។ ដោយអរិជ្ជាមនុស្សភាគច្រើនលើសលប់ក្នុងលោកយើងនេះ គេប្រើតែសមត្ថភាពម៉េម័រីប៉ុណ្ណោះ ។ ចំណែកឯសមត្ថភាពខាងសតិដឹងគេទុកចោលទំនេរអាសារឥតបានការ ។ សតិដឹងនេះហើយដែលជាសារជាតិ និងខ្លឹមសាររបស់មនុស្សយើងម្នាក់ៗ ។ គេសំគាល់មនុស្សមានកម្រិតខ្ពស់ ឬទាបអាស្រ័យដោយមនុស្សនោះបានប្រើសតិដឹងហើយ ឬនៅ ហើយបានប្រើដល់កម្រិតណា? សូមបន្តអានតទៅទៀត អ្នកនឹងបានយល់ដឹងយ៉ាងច្បាស់នូវចំណុចជាមូលដ្ឋាននេះ ។

អាស្រ័យដូចជម្រាបខាងលើនេះ ទើបគេកត់សម្គាល់ឃើញមានមនុស្សពីរពពួក : មនុស្សសាមញ្ញ ឬមនុស្សបូរាណ ពួកគេប្រើតែម៉េម័រីប៉ុណ្ណោះ និងមនុស្សទំនើប ឬអ្នកត្រាស់ដឹង គេប្រើម៉េម័រីព្រមតាំងសតិដឹងទៀតផង ។

ខាងក្រោមនេះ ខ្ញុំសូមលើកយកអធិប្បាយលម្អិតទិដ្ឋភាពនានានៃមនុស្សទាំងពីរប្រភេទនេះ :

**ទី១- មនុស្សបូរាណ ឬមនុស្សសាមញ្ញ**

មនុស្សសាមញ្ញគេវិវត្តឡើងកង្រសត្វ ។ គេបានប្រើប្រាស់ញាណទាំង៦ : ភ្នែក ច្រមុះ ត្រចៀក អណ្តាត ស្បែក និងខួរក្បាល ។ ជាក់ស្តែងគេមានសតិដឹងផងដែរ សម្រាប់ដឹកនាំជីវិតប្រចាំថ្ងៃ ក៏ប៉ុន្តែសតិដឹងរបស់ពួកគេមានកម្រិតផងដែរ សម្រាប់ដឹកនាំជីវិតប្រចាំថ្ងៃ ក៏ប៉ុន្តែសតិដឹងរបស់ពួកគេមានកម្រិតទាបបំផុតនោះ ក៏ព្រោះសតិដឹងនោះមានសភាពលាយឡំចំរុះលំអពណិជាមួយនឹងលំហូរម៉េម័រី ដែលបានថតចម្លងអាត់ទុកក្នុងប្រព័ន្ធរូបកាយ-ចិត្តតាំងពីតូចដឹងក្តីមក ។ ជាក់ស្តែងមនុស្សសាមញ្ញពុំបានរស់នៅពេញលក្ខណៈ១០០%នៃជីវិតឡើយ ។ បើគេហូបបាយអារម្មណ៍គេអណ្តែតត្រសែតទៅលើព្រឹត្តិការណ៍នានាលើកញ្ចក់ទូរទស្សន៍ គេហាក់ពុំបានហូបបាយឡើយ ។ បើគេទៅសម្រាកលំហែកាយមាត់សមុទ្រខួរក្បាលគេពុះពារទៅដោយរឿងស្មុគស្មាញពីកន្លែងធ្វើការ គេពុំបានសម្រាកតាមបំណងឡើយ ។ បើគេកំពុងធ្វើការនៅនឹងដៃរឿងរ៉ាវទំនាស់ប្តីប្រពន្ធគ្រួសារផុះឡើងធ្វើឱ្យគេធ្វើការងារចុងដៃចុងជើង ។ មនុស្សយើងគ្រប់ៗរូបស្ថិតនៅក្នុងសភាពបែបនេះ ។

ខ្ញុំសូមរៀបរាប់អំពីកំណរកំណើតរបស់ម៉េម័រីដែលជាការចងចាំ ឬប្រូក្រាមអាត់ទុកក្នុងប្រព័ន្ធខួរក្បាល និងរូបកាយចិត្តមនុស្សដូចតទៅ:

តាំងពីកើតរហូតមកដល់ពេលនេះ ពេលយើងកំពុងតែអានឯកសារនេះ អ្វីៗដែលមនុស្សយើងធ្លាប់បានឃើញធ្លាប់បានឮធ្លាប់ភ្លក្សរសជាតិ ប៉ះពាល់ ធំក្លិន ពិចារណា និងពិសោធន៍នានាក្នុងជីវិតរបស់ទាំងអស់នោះ រឿងរ៉ាវទាំងអស់នោះ ការពិសោធន៍ទាំងអស់នោះ ពុំបាត់ទៅណាទេ ។ របស់ និងបាតុភូតទាំងអស់នោះសុទ្ធតែបានជិតដាមថតចម្លងជ្រាបចូលទៅក្នុងឃ្លាំងម៉េម័រីទៅក្នុងប្រព័ន្ធខួរក្បាល និងរូបរាងកាយចិត្តមនុស្ស ។ ម៉េម័រី គឺជាឃ្លាំងព័តិមានជាទិន្នន័យ(Data)ដែលបានអាត់ទុកក្នុងខ្លួនមនុស្សតាំងពីកើតមករហូតដល់ពេលនេះតែម្តង ។ យ៉ាងណាមិញបើពេលនេះ អ្នកនឹកភ្នកហៅរក ឬរំលឹកឡើងវិញ រឿងរ៉ាវរបស់អ្នក កាលពីអាយុ៣-៤ឆ្នាំរំពេចនោះ ខ្សែលំហូររូបភាពជាច្រើនផុសឡើងក្នុងខួរក្បាល ហាក់ដូចជារឿងទាំងនោះទើបតែកើតឡើង នាពេលថ្មីៗនេះសោះ ។ ម៉េម័រីនេះប្រៀបដូចជាកញ្ចក់ឆ្លុះមុខដូច្នោះឯង ។ បើអ្នកយកផ្កាទៅដាក់ពីមុខកញ្ចក់កញ្ចក់នឹងឆ្លុះរូបផ្កាចេញមកក្រៅឱ្យអ្នកឃើញ ។ បើអ្នកដាក់លាមកពីមុខវាកញ្ចក់នឹងឆ្លុះរូបបញ្ចូល ឬឆ្លងកាត់ក្នុងជីវិតពុំបាត់ទៅណាឡើយ វាសំងំនៅទីនោះ ជាស្នាមគំនូស (Imprint or inpression) ។ វាទាំងអស់នោះបានក្លាយទៅជាឃ្លាំងព័តិមានជាប្រូក្រាមសម្រាប់បញ្ចេញមកក្រៅវិញ សំរាប់ខ្ទាក់មកក្រៅដូចដំណើរកញ្ចក់ឆ្លុះដូច្នោះឯង ដូច្នេះប្រព័ន្ធម៉េម័រីនេះបង្កើតឡើងនឹងបញ្ចេញមកក្រៅរាល់ៗពេលរាល់នាទីជារលកគំនិតរលកអារម្មណ៍រលកទស្សនៈ ជំនឿ យោបល់ ទំនៀមទំលាប់ ជាសកម្មភាព ពាក្យពេចន៍ អត្តចរិតបុគ្គលិកមនុស្សយើងម្នាក់ៗទៅតាមទិន្ន័យនានាដែលយើងធ្លាប់បញ្ចូលកន្លងមក ។ ម៉េម័រីនេះក្លាយជាអ្នកបញ្ជាប្រព័ន្ធរូបកាយនិងចិត្តនេះដោយផ្តាច់មុខ ។ មនុស្សយើងម្នាក់ៗធ្វើសកម្មភាពសព្វយ៉ាងដើរតាមខ្សែឆ្កួតកាយនេះ ។ មនុស្សពុំអាចឈរក្រៅប្រព័ន្ធម៉េម័រីនេះបានឡើយ ។ មនុស្សជាប់ឃុំក្នុងប្រព័ន្ធម៉េម័រីនេះ រកពុំមានសិទ្ធិសម្រេចខ្លួនឯង គេពុំមានឯករាជ្យខ្លួនឯងឡើយ ។ គេជាអាយ៉ង ឬទីងមោងរបស់ម៉េម័រីនេះ ។ ឥឡូវសូមអ្នកចូលរួមពិនិត្យឧបករណ៍តូចមួយជាមួយខ្ញុំ : ពាក្យសំដីមួយមាត់ដែលបន្លឺចេញមកក្រៅនេះ បើពាក្យនេះមកពីណាមក?

តើពាក្យនេះមកពីណាមក? **តទៅលេខក្រោយ**

# ព្រឹទ្ធសមាជិក អេដ ម៉ាគី



អេដ ម៉ាគី គណបក្សប្រជាធិបតេយ្យបានឈ្នះឆ្នោតលើ គ្លោ មេស គណបក្សសាធារណរដ្ឋ៥៨% ទល់នឹង៤២% នៅរដ្ឋម៉ាសាឈូសែត កាលពីថ្ងៃទី២៥ ខែមិថុនា ហើយបានក្លាយជាព្រឹទ្ធសមាជិកអាមេរិកាំងជំនួសតំណែង ចន ឃែរី ដែលបានលាលែងទៅកាន់តំណែងរដ្ឋលេខាធិការក្រសួងកិច្ចការបរទេសក្នុងរដ្ឋាភិបាលអូបាម៉ា ។ តំណែងនេះមានអាណត្តិតែមួយឆ្នាំប៉ុណ្ណោះ ឆ្នាំក្រោយ ម៉ាគី នឹងឈរឈ្មោះជាបេក្ខជនក្នុងតំណែងដដែលនេះក្នុងអាណត្តិពេញ៦ឆ្នាំ ។

សហគមន៍ខ្មែរនៅឡូវែលនេះក៏មានគុណសម្បត្តិដោយការជួយជ្រោមជ្រែងរបស់ វ៉ាស្នា នួន នឹង **តទៅទំព័រទី ១៨**








តមកពីទំព័រទី ១

# ស្ថានភាពនយោបាយខ្មែរបានផ្លាស់ប្តូរ...

**១-**ឃោសនាបោះឆ្នោតសភាជាតិឆ្នាំ ២០១៣ គណបក្សប្រឆាំងធ្វើបានប្រសើរជាងលើកមុន

-គណបក្សប្រឆាំងរួមបញ្ចូលគ្នារវាងគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធមនុស្សបង្កើតជា "គណបក្សសង្គ្រោះជាតិ" មានរូបរាងដូចគ្នានឹងគម្រូប្រជាធិបតេយ្យនៅបច្ចិមប្រទេស - មេឃុំ និងចៅសង្កាត់នៃគណបក្សប្រឆាំងនេះ ក៏មានចំនួនច្រើនជាងមុនចូលមកកាន់ដំណែងដោយពុំមានខ្លាច ទោះជាមានការបន្តគម្រាមកំហែងពីសំណាក់គណបក្សកាន់អំណាចក្តី -រៀបចំការឃោសនារបស់ខ្លួនទាំងក្នុង និងក្រៅប្រទេសបានប្រសើរហួសពីការប៉ាន់ស្មានដោយមានការកើនចំនួនអ្នកគាំទ្រ -គ្មានសញ្ញាប្រទាញប្រទង់ ឬភាពក្រខ្វក់ផ្ទៃក្នុងណាមួយដែលធ្វើឱ្យអ្នកគាំទ្រខកចិត្តសារជាថ្មីនៅឡើយ -ប្រធានគណបក្ស សម រង្ស៊ី ទោះជាមិនមានវត្តមាននៅក្នុងប្រទេសក្តី ក៏អនុ-ប្រធាន កឹម សុខា ដើរតួរជំនួសបានយ៉ាងគាប់ប្រសើរបានមិនដូចការវិភាគពីពេលមុននោះទេ - កម្មវិធីនយោបាយ "គណបក្សសង្គ្រោះជាតិ" ជាវត្ថុបំណងរបស់ពលរដ្ឋ៩០ភាគរយដែលរស់មិនគ្រប់គ្រាន់នៅសល់តែត្រូវធ្វើយ៉ាងណាឱ្យគេជឿបានថា កម្មវិធីនយោបាយនោះប្រាកដជាអាចធ្វើបានមិនមែនភូតភរយកតែឈ្នះឆ្នោតនោះទេ ។

២-ការឃោសនារបស់គណបក្សប្រជាជនក៏មានថ្មីខ្លះដែរ

ខុសពីសព្វមួយដងស្ថានភាពគំរាមកំហែងបានថយចុះលើកមុនមានឃោធា និងប៉ូលិសនៅវាយពាសពេញដោសមានលេសថា ប្រទេសកម្ពុជាពេលនោះមានប្រកាសភាពអាសន្ន ពីព្រោះត្រៀមធ្វើសង្គ្រាមជាមួយនឹងប្រទេសថៃក្នុងជម្លោះ "ព្រះ-វិហារ" ធ្វើឱ្យលទ្ធផលឃ្លោងទៅគណបក្សកាន់អំណាចបានលើស២ភាគ៣ - ការឃោសនាបោះឆ្នោតសភាជាតិលើកទី៥នេះគណបក្សប្រជាជននៅតែបង្ហាញពីភាពជរាចាស់ទ្រុឌទ្រោមរបស់ថ្នាក់ដឹកនាំរបស់ខ្លួននៅឡើយ - មានការជម្រុញឱ្យឈាមថ្មីនៃអ្នកយុវបញ្ញវន្តគណបក្សជំនាន់ ក្រោយចេញមកជំនួសបានតិចតួច ហើយពុំទាន់មានបទពិសោធន៍ -បច្ចេកវិធីឃោសនាតាមវិធីប្រើលុយទិញទឹកចិត្តមិនបានផ្លាស់ប្តូរ - ប្រើអំណាចរដ្ឋ និងប្រើ គ.ជ.ប ប្រើសភាជាតិ ដើម្បីប្រយោជន៍ផ្ទាល់ដដែល -គណបក្សប្រជាជនសំអាងលើសមិទ្ធិផលជាតិជាគំរូសម្រាប់បង្ហាញពីកម្មវិធីនយោបាយអនាគតរបស់គណបក្សខ្លួន -ប្រើអំណាចបក្សសម្លេង២ភាគ៣ កាត់អភ័យឯកសិទ្ធកាត់តួរនាទី និងកាត់ប្រាក់ខែសមាជិកសភាក្នុងអណត្តិ -ក្នុងអាណត្តិចុងក្រោយដែលគណបក្សប្រជាជនកាន់អំណាចសភាជាតិលើស២ភាគ៣មិនមានសេចក្តីសម្រេចធ្ងន់ធ្ងរកែប្រែលើរដ្ឋធម្មនុញ្ញណាមួយដែលនាំឱ្យកម្ពុជាកែមិនឡើងក្រៅតែពីបញ្ហាព្រំប្រទល់ដែនជាមួយវៀតណាមនោះទេ

៣-លក្ខណៈអវិជ្ជមានថ្មីៗនាឱកាសបោះឆ្នោត

-មហាបាតុកម្មរៀបចំដោយគណបក្សកាន់អំណាចគាំទ្រអតីតអ្នកទោសគុកទួលស្លែងក្នុងបំណងផ្ទាញ់ផ្ទាលបក្សប្រឆាំងបានទទួលលទ្ធផលបរាជ័យមិនបានប៉ះពាល់ដល់ការឃោសនានៃបក្សប្រឆាំងទេ -ការបិទមិនឱ្យផ្សាយវិទ្យុបន្តពីបរទេសបានទទួលការរិះគុណថ្កោលទោសដល់រដ្ឋាភិបាលនៃគណបក្សកាន់អំណាចយ៉ាងធ្ងន់ធ្ងរធ្វើឱ្យរដ្ឋាភិបាលសម្រេចឱ្យបើកឡើងវិញនេះបង្ហាញចេតនារដ្ឋាភិបាលបំបិទសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ -ចលនាប្រជាជន "បឹងកក់" មិនសប្បាយចិត្ត និងការចាប់ចងសកម្មជនរបស់ខ្លួនជាម្ចាស់ដីបានក្លាយជាបាតុកម្ម និងកូដកម្មដែលធ្វើឱ្យរដ្ឋាភិបាលកាន់តែមានមុខមាត់រិតតែអាក្រក់តែបានជាអំណោយផលដល់បក្សប្រឆាំងនាឱកាសមុនបោះឆ្នោត

៤-បច្ចេកទេសដែលធានាជ័យជំនះឱ្យគណបក្សប្រជាជនគណបក្សប្រឆាំងធ្លាប់និយាយថា "គណបក្សកាន់អំណាចគ្រប់គ្រងសន្លឹកឆ្នោតបានតែ២លានសម្លេងទេ នៅសល់៥លានសម្លេងទៀតដែលត្រូវប្រមូលឱ្យមូល ដើម្បីយកជ័យជំនះលើគណបក្សប្រជាជន" ។ មែន! ពីមុនមកសម្លេង៥លាននោះ ក៏មានចំណែកបន្ថែមរបស់គណបក្សប្រជាជនដែរ រីឯសម្លេងដែលនៅសល់ ក-គេបង្កើតគណបក្សរណបសម្រាប់មកចែកសម្លេងជាមួយបក្សប្រឆាំង ខ-ការប្តូរមណ្ឌលបោះឆ្នោតដោយមិនប្រាប់មុនលើកលែងតែក្រុមដែលគ្រប់គ្រងដោយគណបក្សប្រជាជន គ-បង្កើនអារម្មណ៍ភ័យខ្លាច ឬបង្កើតការលំបាកដល់អ្នកដែលមិនជាក់ច្បាស់ថា នឹងបោះឆ្នោតឱ្យគណបក្សប្រជាជនមិនឱ្យទៅបោះឆ្នោត ឃ-នៅមណ្ឌលជនបទឆ្ងាយៗដែលគ្មានបេក្ខជនគណបក្សប្រឆាំងសម្លេងឆ្នោតបានទៅគណបក្សប្រជាជនទាំងអស់ ង-ថ្ងៃបោះឆ្នោតបំភ័យអ្នកមកបោះឆ្នោតថា "គេនឹងដឹងថាអ្នកឯងបោះឆ្នោតឱ្យនរណា" ឬបង្កើតឱ្យមានការរវល់មិនអាចមានពេលមកបោះឆ្នោតបាន ច-ពេលរាប់សន្លឹកឆ្នោតមានការបន្លំរាប់សន្លឹកឆ្នោតគណបក្សផ្សេងថា "ជាសន្លឹកឆ្នោតគណបក្សប្រជាជន" ឆ-ការដាក់ពាក្យប្តឹងចំពោះការលួចបន្លំភាពមិនប្រក្រតីនៃសន្លឹកឆ្នោតមិនបានត្រូវទទួលយកមកកាត់ក្តីឱ្យបានយុត្តិធម៌ទេ ជ-ការបែងចែកអាសនៈឱ្យច្រើនដល់អ្នកដែលទទួលបានសន្លឹកឆ្នោតច្រើនជាងគេ ។ល។

៥-បច្ចេកទេសនៃគណបក្សប្រឆាំង

កន្លងមកបក្សប្រឆាំងនិងគណបក្សរណបគ្មានអំណាចលូកលាន់កិច្ចការបោះឆ្នោតអ្វីទាំងអស់លើកលែងតែសមាជិកសភា **តទៅទំព័រទី១៨**




# ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

**Rathe's Auto Service**

State and Emission Inspaction General Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងកំរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

# ក្រុមហ៊ុនទេសចរណ៍

- បំរើលោកអ្នកដោយគ្រប់ក្រុមហ៊ុនអាកាសចរណ៍ សំរាប់ដំណើរហើរក្នុង និងក្រៅស្រុក
- ជួយរកអ្នកនាំផ្លូវជូនដំណើរទស្សនកិច្ចធ្វើការ
- ពន្យាលិខិតឆ្លងដែនខ្មែរ
- ធ្វើលិខិតអន្តោប្រវេសន៍
- ធ្វើទិដ្ឋាការសំរាប់ទេសចរណ៍
- ផ្ញើប្រាក់ប្រថាប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

CENTURY TRAVEL & SERVICE CENTER
**904 South 8th Street. Philadelphia, PA 19147**
**Tel : 215-625-2889; Cell : 267-934-9888**

# ខ្មែរជួសជុលរថយន្ត
# KHMER AUTO REPAIR

**CAR INSPECTION, DIAGNOTIC & REPAIR**

**ត្រួតពិនិត្យរថយន្តបញ្ញរដ្ឋ**
- ឆែករកកន្លែងខូចខាត និងជួសជុល
- យើងធ្វើហ្វ្រាំង ឬប្រេក
- ត្រួតពិនិត្យធ្វើម៉ាស៊ីនឱ្យស្រួលឡើងវិញ
- បញ្ចេះឡានអាល់ទេណាទ័រ
- បូមចរន្តទឹកវេឌីណាទ័រ
- សេវាត្រង់បីស្យង
- មើលតម្រងទ្រនាប់ និងពីញ៉ង

Brake Service
Turn up electronic
Starters Alternators
Radiators water pumps
Transmission Service
Struts checked & serviced
CV Joints Rack & Pinion
Shocks checked & Replace

115 West. Tabor Rd, Philadelphia, PA 19120
Tel: (215) 455-1422/Pat: 215-939-5634

ជោគជតាប្រចាំសប្តាហ៍

# ជោគជតារាសីទាំង 12 ប្រចាំឆ្នាំហាង

**ឆ្នាំជូត**

លោកអ្នកគួរប្រុងប្រយ័ត្នចំពោះការនិយាយស្តីបន្តិច ពីព្រោះអាចនឹងមានគួសត្រូវចាំចាប់ទោសកំហុសមួលបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះរបស់លោកអ្នកឱ្យប្រែក្លាយទៅជាស្អុយអសោចិ៍ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញមានក្រុមមនុស្សតាមឈ្នានីសច្រើន ដូចច្នេះត្រូវប្រយ័ត្នបន្តិចចៀសវាងការបរាជ័យ ។ រីឯបញ្ហាស្នេហាមានភាពចម្រូងចម្រាសដាក់គ្នាបន្តិចបន្តួច ៕

**ឆ្នាំថោះ**

នៅក្នុងរយៈពេលនេះ លោកអ្នកទទួលលាភសក្ការៈពីសាច់ញាតិបងប្អូនដែលជិតស្និទ្ធ ។ ក្រៅពីនោះក៏នៅទទួលបានដំណឹងល្អដែលមានប្រយោជន៍ដល់ជាតិនិងការងាររបស់លោកអ្នកតទៅអនាគតទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញផលកម្រៃទទួលបានកាក់កបគ្រាន់បើ តែហាមកុំជួញដូរផ្លូវឆ្ងាញប្រយ័ត្នមានបញ្ហាដល់ខ្លួន ។ រីឯបញ្ហាស្នេហាគូស្នេហ៍អាចមានការរកាំរកូសគ្នាខ្លះ ប៉ុន្តែមិនធ្ងន់ធ្ងរនោះទេ ៕

**ឆ្នាំមមី**

ក្នុងរយៈពេលនេះលោកអ្នកជួបនឹងបញ្ហាខាងផ្លូវចិត្តមិនសូវជាសប្បាយរីករាយប៉ុន្មាននោះទេ តែប្រសិនបើចង់ទទួលផលពីការងារនោះ ចូរធ្វើចិត្តឱ្យត្រជាក់ ទើបបានសម្រេចដូចបំណង ។ បើជាអ្នកប្រកបរបររកស៊ីជួញដូរវិញ គឺមានការប្រទាំងប្រទើសជាមួយអ្នកមានមុខរបរដូចគ្នា ដូច្នេះគួរបើកចិត្តឱ្យទូលាយ ។ រីឯបញ្ហាស្នេហាមានការកាំចិត្ត ព្រោះតែម្នាក់ៗចង់ចាញ់ឈ្នះគ្នានោះឯង ៕

**ឆ្នាំរកា**

រាល់ការបំពេញការងារទាំងឡាយលោកអ្នកមិនមានបញ្ហាអ្វីចោទនោះទេ ប៉ុន្តែក្នុងនោះសូមប្រយ័ត្នកុំយកអាសាមនុស្សសម្បុរសឱ្យសោះ ព្រោះនាំឱ្យកើតរឿងសៅហ្មងទៅថ្ងៃក្រោយ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចសន្សំទុកបានខ្លះ ។ រីឯបញ្ហាស្នេហាចូរកុំយកភាពមានះចង់ចាញ់ឈ្នះប្រយ័ត្នកើតមានជម្លោះវិវាទឈានដល់ការប្រេះស្រាំ ៕

**ឆ្នាំឆ្លូវ**

រាល់ការស្នេហ៍ស្នាញដែលធ្លាប់កើតមានលើលោកអ្នកក្នុងពេលនេះ នឹងត្រូវអហោសិកម្មទាំងអស់ ហើយទ្រព្យដែលរបូតចេញពីដៃទៅនឹងវិលត្រឡប់មកវិញយ៉ាងគ្រប់គ្រាន់ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ ត្រូវគិតគូរឱ្យបានច្បាស់លាស់មុននឹងដាក់ទុនថ្មី ទើបមិនខាតបង់រាល់ការចំណាយទាំងនោះ ។ រីឯបញ្ហាស្នេហាត្រូវចេះពូនជ្រោយចំណងស្នេហាដោយមានភាពផ្អែមល្ហែមទើបជាការប្រសើរ ៕

**ឆ្នាំរោង**

លោកអ្នកអាចនឹងមានអារម្មណ៍ច្របូកច្របល់បន្តិចនៅក្នុងរយៈពេលនេះ ព្រោះកិច្ចការដែលថា នឹងទទួលបានផលល្អនោះ វាអាចមានការប្រែប្រួលដោយសារតែមានការរំខានពីអ្នកដទៃ ។ បើចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចរកផលកម្រៃគ្រាន់បើគួរជាទីគាប់ប្រសើរជាងមុន ។ រីឯបញ្ហាស្នេហាពុំមានផលរមាស់អ្វីនោះឡើយ ៕

**ឆ្នាំមមែ**

អាចពោលបានថា លោកអ្នកមានសេចក្តីសុខក្នុងជីវិត និងការងារ ព្រោះវិបត្តិ និងភាពស្មុគស្មាញដែលមានកន្លងមកក៏បានធូរស្រាលឡើងវិញមួយកម្រិតផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ ទោះបីជាចេញទៅជួញដូរនៅទីណាក្តីគួរចៀសវាងការដាក់ទុនថ្មី ព្រោះអាចនាំឱ្យខាតបង់ ។ រីឯបញ្ហាស្នេហាគូស្នេហ៍ច្រើនប្រចណ្ឌខុសរឿង ៕

**ឆ្នាំច**

លោកអ្នកមានភ័ព្វសំណាងល្អក្នុងការងារទទួលរឿងឡើងតួនាទី ឬប្រាក់បៀវត្សរ៍បន្ថែម ។ ជាងនេះទៀតនោះ ប្រសិនបើចង់ពឹងពាក់អ្នកមានយសស័ក្តិខ្ពង់ខ្ពស់ក្នុងរឿងអ្វីមួយនឹងបានដូចបំណងផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចរកប្រាក់ចំណូលចិញ្ចឹមគ្រួសារបានដោយស្រួលទេ មិនមានអ្វីមករាំងស្ទះឡើយ ។ រីឯបញ្ហាស្នេហាគូស្នេហ៍រមែងចេះអត់ឱនឱ្យគ្នា ៕

**ឆ្នាំខាល**

រាល់កិច្ចការដែលលោកអ្នកប៉ងប្រាថ្នាជាយូរមកហើយនោះក្នុងរយៈពេលនេះ គឺបានសមដូចបំណងហើយគ្មានអ្វីមករារាំងនោះទេ ហើយរាល់ការប៉ងឃាយីពីមនុស្សដែលមានបំណងមិនល្អមកលើលោកអ្នកនោះក៏មិនបានសម្រេចដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចពង្រីកអាជីវកម្មឱ្យធំបន្ថែមទៀតបាន ។ ឯបញ្ហាស្នេហា គូស្វាមីភរិយាមានភាពសុខដុមរមនាគ្មានផលរមាស់អ្វីឡើយ ៕

**ឆ្នាំម្សាញ់**

រាល់កិច្ចការសព្វបែបយ៉ាងលោកអ្នកអាចជួបនឹងបញ្ហាខ្លះៗនាគ្រាដំបូង ប៉ុន្តែក្រោយមកមិនមានអ្វីជាឧបសគ្គរារាំងទៀតឡើយ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ មានការទិញចូលលក់ចេញគ្រាន់ បើអាចរកផលកម្រៃត្រឡប់មកផ្ទះវិញយ៉ាងត្រជាក់ចិត្ត ។ រីឯបញ្ហាស្នេហាមានភាពផ្អែមល្ហែម និងស្រស់ស្រាយប្រៀបដូចត្រីក្នុងទឹកនារដូវខែវស្សាដូច្នេះដែរ ៕

**ឆ្នាំវក**

លោកអ្នកនឹងទទួលបាននូវលាភសក្ការៈពីភាគហ៊ុនរកស៊ី និងមិត្តរួមការងារយ៉ាងច្រើនគួរឱ្យពេញចិត្ត ។ លើសពីនេះទៅទៀតគម្រោងការដែលបានត្រៀមទុកនឹងបានសម្រេចដូចបំណងទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ គួរជួញដូរនៅទីជិតៗ ទើបសមប្រកប ។ រីឯបញ្ហាស្នេហាគូស្នេហ៍ចេះស្តាប់ឱវាទគ្នា ៕

**ឆ្នាំកុរ**

រាល់ការបំពេញការងាររបស់លោកអ្នកក្នុងរយៈពេលនេះ សុទ្ធតែផ្តល់នូវអត្ថប្រយោជន៍គួរឱ្យជាទីពេញចិត្តទាំងអស់គ្មានអ្វីមករាំងស្ទះឡើយ ហើយជាងនេះទៀត នោះគម្រោងការដែលបានត្រៀមទុកជាយូរមក ហើយក៏នឹងបានសម្រេចផងដែរ ។ បើជាអាជីវកររកស៊ីវិញ មានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ រីឯបញ្ហាគូស្នេហ៍ច្រើនយល់ចិត្តគ្នា និងនឹករលឹកគ្នាបើនៅឆ្ងាយ ៕


## ក្រុមហ៊ុនធានារ៉ាប់រងដែលបានបំរើសង្គម២២ឆ្នាំហើយ

## CONWAY INSURANCE



For over 23 years, **Conway Insurance Agency** has been your community's one-stop provider of quality insurance services in New England.
We are a **full-service agency** offering:

- Personal Insurance
  - Autos
  - Homes
  - Apartments
  - Jewelry
  - Fine arts
  - Collectibles
- Business Insurance
  - Property
  - Liability
  - Professional Liability
  - Worker's compensation
  - Bonds
  - Auto, Garage keepers.
  - Disability and life insurance (individual and group products)
  - Other specialty programs

ក្រុមហ៊ុនធានារ៉ាប់រង ផ្ទះ រថយន្ត មុខរបរ និងសុខភាព

**យើងនិយាយភាសាខ្មែរ**

CONWAY INSURANCE AGENCY

P.O. Box 1744
77 E. Merrimack Street
Lowell, MA 01853
Tel: 978-454-5054
Fax: 978-453-2480

**www.ConwayInsurance.com**

សូមសួររក Philip Muth, Philip@ConwayInsurance.com



## East Coast Center

for Plastic & Laser Surgery

Mai Ngoc Tran, M.S., Skin Care Specialist
Joseph A. Russo, M.D. F.A.C.S
Plastic & Reconstructive Surgeon
www.eastcoastsurgery.com




**ហាងកែសម្ផស្សយើងខ្ញុំមានទទួលកែសម្ផស្ស បុរស_ស្ត្រី ដែលមានអាការៈដូចជាៈ ខ្លាញ់ក្បាលពោះ ពង្រីកសុដន់ឱ្យធំ កែខ្ទង់ច្រមុះ កែត្របកភ្នែក កែមុខស្រស់ស្អាត...។ល។ និង។ល។ និងមានលក់ឧបករណ៍កែសម្ផស្សផ្សេងៗជាច្រើនទៀត**

381 West Broadway South Boston, MA 02127
**(617) 464 - 0001**

តមកពីទំព័រទី ១

## ស្ថានភាពនយោបាយខ្មែរបានផ្លាស់ប្តូរ...

ឬក្រុមប្រឹក្សាឃុំ-សង្កាត់ ទើបមានទឹកមាត់ប្រែ ឃាត់ឃាំងអំពើទុច្ចរិតបានខ្លះ ។ នៅមានប្រព័ន្ធផ្សព្វផ្សាយវិទ្យុ និងកាសែតបរទេសក៏អាចជាជំនួយសម្រាប់ចង្អុលមុខអំពើអយុត្តិធម៌របស់អ្នកកាន់អំណាច ក៏ប៉ុន្តែពុំបានធ្វើឱ្យប្តូរលទ្ធផលនៃការបោះឆ្នោតម្តងណាទេ ។ ព្រឹត្តិការណ៍ថ្មីបំផុតក្នុងការបោះឆ្នោតលើកនេះដំណើរការណ៍មិនដូចលើកមុនទេ ដោយសារគណបក្សសង្គ្រោះជាតិមានគ្នាច្រើនជាងមុនមាន ការគ្រប់គ្រងប្រសើរជាងមុន មានការគាំទ្រទូលំទូលាយជាងមុនមានការដាក់បេក្ខជនបានគ្រប់មណ្ឌល មានទំហំធំជាងគណបក្សរណបទាំងអស់ដែលពេលនេះអាចរាប់បានថា "សមជាគូរប្រកួតជាមួយគណបក្សប្រជាជនបាន" ជាពិសេសកម្មវិធីនយោបាយដ៏ក្លាហានហ៊ានប្រកាសថា"នឹងតម្លើងជីវភាព កម្មករ កសិករ មន្ត្រីរាជការ មនុស្សចាស់ជរា គាំទ្រដល់យុវជន ដល់ការអប់រំ ដល់សុខភាពមហាជន..." ដែលក្នុងសមិទ្ធផលរបស់គណបក្សប្រជាជនពុំទាន់អាចធ្វើបាននៅឡើយ ហើយក៏ពុំហ៊ានជម្រុញឱ្យទៅដល់គំរិតនោះបានទេ ដូច្នេះមានតែចំអកថា "ជាការមិនពិតមិនអាចធ្វើបាន" តែគណបក្សប្រឆាំងបានលើកយកសេចក្តីរាយការណ៍រៀងរាល់ឆ្នាំ ដែលថា"មានការបាត់លុយរដ្ឋដោយអំពើពុករលួយចំនួនជាង១៤០០លានដុល្លារ ហើយការទប់ស្កាត់អំពើពុករលួយនោះនឹងបានថវិការសម្រាប់តម្លើងជីវភាពពលរដ្ឋបានភ្លាម"។ ប្រធានគណបក្សសង្គ្រោះជាតិ គឺលោក សម រង្ស៊ី ក៏ធ្លាប់មានស្នាដៃក្នុងការបង្ក្រាបអំពើពុករលួយយ៉ាងល្បីល្បាញ នាឆ្នាំ១៩៩៣-៩៤ កាលលោកនៅជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ដូច្នេះស្នាដៃនេះអាចធ្វើឱ្យមនុស្សជាច្រើនជឿថា "ពិតជាធ្វើបាន"។ ៦-ស្រាប់តែនៅពេលដែលយើងកំពុងសរសេរបទវិភាគនេះព័ត៌មានមួយធ្លាក់មកដល់និយាយថា "លោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិនឹងត្រឡប់ទៅចូលរួមដង្ហែរក្បួនឃោសនានៅកម្ពុជាមុនពេលបោះឆ្នោត" ធ្វើឱ្យយើងមានការរន្ធត់នឹកទៅដល់គំរូនៃហ្វីលីពីននៅពេលដែលបណ្ឌិត អាគីណូ មេបក្សប្រឆាំងដ៏ល្បីល្បាញចុះពីយន្តហោះនៅក្រុងម៉ានីល នាមុនពេលបោះឆ្នោតលោកប្រធានាធិបតីផ្តាច់ការនិយម ម៉ាកូស បានចេញបញ្ជាឱ្យឃោធាបាញ់សម្លាប់... នេះក៏អាចជាវាស្នាលោក សម រង្ស៊ី បានដែរ ឬក៏មួយទៀត មានការនាំខ្លួនទៅចូលគុកព្រៃសតែម្តង ។ វាស្នា ទាំង២នេះ មានរូបភាពអភ័ព្វណាស់ តែគេពុំអាចទស្សន៍ទាយបានពីទំហំនៃកំហឹងមហាជនដែលលែងខ្លាចស្លាប់ថា "តើមានកម្លាំងប៉ុណ្ណា?" នោះណាស់ ។ ម៉ាកូស បានរបូតពីអំណាចដ៏រឹងមាំរបស់ខ្លួនយ៉ាងទាន់ហន់ដោយសារកំហឹងប្រជាជនហ្វីលីពីននាពេលនោះ ។ គណបក្សសង្គ្រោះជាតិនៅមានធនធានមនុស្សច្រើនទៀត ដែលអាចបន្តអំណាចបក្សប្រឆាំងមិនឱ្យរលត់បាន ហើយក៏មានសមត្ថភាពកាន់ចង្កូតអំណាចរដ្ឋបានផង ដូចជា លោក កឹម សុខា -លោកស្រី ជូឡុង សូមួរា - លោកស្រី មូ សុខហួរ - លោកសុន ឆៃ លោកគង់ គាំ ។ល។ រួមទាំងយុវបញ្ញាវន្តសសរទ្រូងមួយចំនួនធំដែលមានស្នាដៃតស៊ូប្រឆាំងនឹងរបប ហ៊ុន សែន ក្នុងសភា និងក្រៅសភាជាតិដែលសុទ្ធសឹងកាត់ជាតម្លៃមិនបានរាប់មិនអស់ច្រើនទៀត ។

៧-នាទីនៃការផ្លាស់ប្តូររបបបានមកដល់

ការមកដល់កម្ពុជារបស់ សម រង្ស៊ី ដោយគ្មានញញើតអំណាចក្រុមលោក ហ៊ុន សែន គឺ ១- ជាការប្តូរដៃនៃ"អ្នកខ្លាច"ដែលពុំមែនជាអ្នកបោះឆ្នោតឱ្យគណបក្សប្រឆាំង គឺអ្នកបំរើការងារទុច្ចរិតឯណោះទៅវិញទេ ២-បង្កើនបាមពលឱ្យពលរដ្ឋកាន់តែច្រើន ហ៊ានចេញមុខគាំទ្រយុត្តិធម៌ គាំទ្រសិទ្ធរបស់ខ្លួនឯង ៣-អាចជម្រុញរដ្ឋាភិបាលឱ្យច្រឡំធ្វើសកម្មភាពហឹង្សាណាមួយក្នុងទម្លាប់អ្នកកាចដែលនឹងបំផ្លាញទាំងខ្លួនឯងទាំងគណបក្សទាំងមូលរឹតតែឆាប់បាន ។

តែទោះជាយ៉ាងណាក្តីលោក សម រង្ស៊ី បាននិយាយ "សូមបូជាជីវិតជូនប្រជាជាតិ" គឺមានតែពេលនេះទេ ដែលពាក្យនេះ មានន័យខ្ពស់... ស្លាប់ឬនៅរស់លោក សម រង្ស៊ី នឹងធ្វើឱ្យចំនួនសន្លឹកឆ្នោតកើនរហូតដល់គណបក្សសង្គ្រោះជាតិឈ្នះបាន បើមិនដូច្នោះទេ ប្រជាជាតិទាំងមូលនិង បូជាព្រលឹងរបស់ខ្លួនជាមួយព្រលឹងលោក សម រង្ស៊ី ជាប្រាកដ រហូតដល់មានការផ្លាស់ប្តូរអំណាចចេញពីគណបក្សប្រជាជនដោយបង្ខំ ៕

តមកពីទំព័រទី ១៤

## ព្រឹទ្ធសមាជិក អេដ ម៉ាគី...

រិទ្ធី អ៊ុង ដែលជាបច្ចុប្បន្ននឹងអតីតសមាជិកគណក្រុមប្រឹក្សាក្រុងឡូវែលណែនាំឱ្យបងប្អូនខ្មែរជាច្រើនមករួបរួមប្រជុំនៅភោជនីយដ្ឋានប៉ៃលិន ដើម្បីស្វែងរកការគាំទ្រឱ្យ អេដ ម៉ាគី នៅ១សប្តាហ៍មុនពេលបោះឆ្នោត ។

# Senator Markey

**By Richard P. Howe Jr.**

On June 25, 2013, Edward Markey, a Democratic Congressman for the past 37 years, was elected to the United States Senate by the voters of Massachusetts.




Markey defeated Gabriel Gomez statewide, 55% to 45%, in a special election that saw only 27% of the state's registered voters participate by voting in the election.

Markey won the city of Lowell, 58% to 42% (5656 votes to 4150 votes) and almost every big city in the state including Boston, Worcester, Springfield, Fall River, New Bedford, Brockton and Lawrence. Gomez won a great many towns both south and north of Boston. In Greater Lowell, Gomez won the towns of Dracut, Tyngsborough, Tewksbury, Billerica, Westford and Chelmsford, however, the votes from those towns were not sufficient to overcome the votes from the cities.

The big victory for Markey in Lowell was partly due to the hard work of many volunteers in the city but his campaign received a big assist on the Sunday before the election when City Councilor Vesna Nuon and former City Councilor Rithy Uong organized a rally for Ed Markey at Pailin City which was attended by many Cambodian people of Lowell.

This special election was necessary when John Kerry resigned from the U.S. Senate to become Secretary of State. Because Ed Markey was only elected to complete John Kerry's term in the Senate, Markey must run again for a full six-year term in the 2014 state election.

តមកពីទំព័រទី ៩

## បច្ចុប្បន្ននៃផែនការអភិវឌ្ឍន៍ក្រុងខ្មែរ...

រៀងរាល់ថ្ងៃពលរដ្ឋខ្មែរអាមេរិកាំងគ្រប់ប្រភេទ និងគ្រប់វ័យប្រហែល១៥០-២០០នាក់ បានមកលំហែកំសាន្តក្នុងឧទ្យានប៉ៃលិន ដូចជាលេងបាល់ទះ បាល់បោះ បោះប៊ូល ទាត់សី ឬយុវជនលេង Roll Skate ជាដើម ។

សមិទ្ធិផលត្រួស១ដូចជារៀបរាប់ខាងលើនេះមិនអាចកាត់ផ្តាច់បានពីការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ និងកម្លាំងចិត្តរបស់លោក វាស្នា នួន សមាជិកក្រុមប្រឹក្សាក្រុងឡូវែលក្រោមការដឹកនាំប្រកបដោយសមធម៌ និងមុទិតាធម៌របស់លោកចៅហ្វាយក្រុង Patrick O. Murphy ។

លោក វាស្នា នួន ក្នុងនាមជាសមាជិកក្រុមប្រឹក្សាក្រុង ក៏ដូចជាសមាជិកសហគមន៍ខ្មែរមួយរូបជានិច្ចកាលតែងតែទាមទារឱ្យមានការវិនិយោគលើវិស័យអាទិភាព (Priority areas) មួយចំនួនដែលបំរើឧត្តមប្រយោជន៍របស់សហគមន៍ និងក្រុងខ្មែរឡូវែល ។ លោកគឺជាអ្នកផ្តួចផ្តើមទាមទារឱ្យមានការកែលំអឧទ្យានសាធារណៈប៉ៃលិន ។



លោកបានបោះឆ្នោតគាំទ្របញ្ចប់ថវិការមួយរបស់សាលាក្រុងដែលធានាមិនឱ្យមានការឡើងពន្ធដារ ព្រមទាំងផ្តល់ថវិកាសំរាប់គម្រោងកែលំអឧទ្យានសាធារណៈនានានៅទីក្រុងឡូវែល ពីព្រោះលោក វាស្នា នួន មានជំនឿយ៉ាងមុតមាំថា បរិស្ថានក្រុងល្អនាំឱ្យពលរដ្ឋមានសុខភាពល្អ ពលរដ្ឋមានសុខភាពល្អនាំឱ្យគ្រួសារសុខសាន្តគ្រួសារសុខសាន្តនាំឱ្យសហគមន៍មានស្ថេរភាព សន្តិភាព សាមគ្គីភាព និងវឌ្ឍនះភាព ៕

**ផ្ទះសំរាប់ជួល**

-ផ្ទះ Single House នៅ Chelmsford Mass ជិតមណ្ឌលពាណិជ្ជកម្ម មានបីបន្ទប់គេង បន្ទប់ទទួលភ្ញៀវ បន្ទប់បាយ បន្ទប់បោកខោអាវ មានផ្លូវចូលធំ មានទទួល Section 8
-មាន ២បន្ទប់គេង នៅក្បែរផ្សារបាត់ដំបង សំរាប់ជួលដែរ
ទូរស័ព្ទ : **(978) 967-6695**
**(978) 987-3766**

**លក់ហាងហ្វ្រូហ្សិនយ៉ូហ្គឹត**

ឱកាសក្លាយជាម្ចាសខ្ញុំហាងហ្វ្រូហ្សិនយ៉ូហ្គឹត។ ហាងទើបតែចាប់ផ្តើមបើកថ្មី១នៅវីលមីងតុង (Wilnington)។ យើងត្រូវការលក់ហាងនេះ ។ គ្មានបទពិសោធន៍ជំនួញនេះក៏អាចធ្វើបានដែរ ហើយងាយស្រួលរៀបចំថែមទៀត ។ ថ្លៃលក់ហាងថោកជាងថ្លៃដែលបានចំណាយសាងសង់ហាង ។
ថ្លៃលក់ហាង : **$200,000**
ប្រាក់ចំណូលអាចរកបាន : **$10,000** ឬច្រើនជាងនេះ ។
សូមហៅមកកាន់ : **978-967-6695**

# AccuCare Homecare Agency

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

Group Adult Foster Care Program (GAFC)
MassHealth

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្ដានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ



*Compassionate Care & Reliable*
*Professional & Cultural Sensitive*
*Management & Staffs speak Khmer*

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារ៉ាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្ដល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្ដង ។

*Accucare Homecare Agency is the perfect solution for seniors and others who are not ready to leave their home for an institutional setting or live with reltives because of illness or chronic conditions. We improve your life by providing one-on-one compassionate senior care in the comfort of your own home.*

### ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :

To be eligibled for GAFC you must:

- រស់នៅផ្ទះរដ្ឋ (live in subsidized or public housing)
- អាយុ ២២ ឆ្នាំឡើងទៅ (age 22 years and older)
- មានប័ណ្ណម៉ាស់ហែលស្តង់ដា (eligible for Masshealth Standard)
- ត្រូវការជំនួយក្នុងការរស់នៅប្រចាំថ្ងៃយ៉ាងហោចណាស់មួយដូចជា មុជទឹក ស្លៀក-ពាក់ ពេលប្រើបន្ទប់ទឹក ចំអិនអាហារ ឬ ពេលដើរ (need daily assistance with one or more personal care tasks such as bathing, dressing, toileting, meal preparation and/or moving)
- មានការអនុញ្ញាតពីគ្រូពេទ្យផ្ទាល់ខ្លួនអ្នក (have physician statement of your condition)
- ត្រូវបានវាយតំលៃផ្នែកសុខភាព និងការអនុម័តយល់ព្រមពីកម្មវិធី (be screened and approved for the program )

### ផលប្រយោជន៍ទទួលបាន :

Benefits you will get:

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ (personal care service in your home, up to one hour of service each day)
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក (Medication Managemant)
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសម៉ានីជើ (an individual care plan developed by a registered nurse and case manager)
- វាយតំលៃលើសេចក្ដីត្រូវការជាប្រចាំជាបន្តបន្ទាប់ (ongoing monitoring of needs)
- សមាជិកអាចទាក់ទងមក ២៤ម៉ោង (24-hour access to services)

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:



ឱក តុលាយុត្ថិ ឡូវែល
Tolayuth Ok: Lowell
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852



ពិន ឆាវ៉ាន់ លីន រីវៀរ បុស្តុន
Chhavan Pin: Lynn, Revere, Boston
Tel:(617)783-7177, Fax: (617) 783-7188
Office: 214 Lincoln St., Suite 200. Allston, MA 02134

# ភ្នំឡាបប៉ៃលិន

**GRAND OPENING**

Asian & International foods Market

## ហាងឧបភោគបរិភោគ ទើបប្ដូរម្ចាស់បើកថ្មី




**6 Branch St. Lowell MA 01851 (978)-459-1780**

- មានលក់បន្លែបង្កាស្រស់គ្រប់មុខ មានផ្លែឈើមកដល់ថ្មីរាល់ថ្ងៃ
- ត្រីសាច់ គ្រឿងសមុទ្រ ម្ហូបហាលស្ងួត គ្រឿងកំប៉ុង ម្ហូបគ្រប់យ៉ាង មកពីអាស៊ី -អង្គរគ្រប់ជន
- មានម្ហូបឆ្អិនស្រេច ជាកឡូរ ទាខ្វៃ ចៅខ្វៃ នំនែក ។ល។
- មានតាំងចុះថ្លៃច្រើនមុខរាល់ថ្ងៃ :

យើងទទួល Credit Card គ្រប់យ៉ាងទទួល Food Stamp Card
មានកន្លែងចតរថយន្តខាងមុខ និងខាងក្រោយហាងធំទូលាយ

DISCOVER VISA MasterCard SNAP

**Fresh Produce**

- Poultry
- Meats
- Fish and Seafoods
- Veggebles
- Can foods
- Kitchenwares etc

**ម៉ោងបើកចាប់ពីម៉ោង៩:00AM-៨:00PM**



កំប៉ុងធំ $7.99



កំប៉ុងតូច $3.99



អង្ករខ្មែរមាសសរ $15.99



| | | | | | |
|---|---|---|---|---|---|
| $3.75 /ដប | $3.75 /កញ្ចប់ | $1.99 /កំប៉ុង | $1.99 /កញ្ចប់ | ខ្ទិះសដូង $1.25/កំប៉ុង ប្រអប់$24( 24កំប៉ុង ) | $11.99 /ប្រអប់ |







# Now I have someone to drive me to the doctor.

With **UnitedHealthcare® Senior Care Options (HMO SNP),** you'll have a Personal Care Manager. Your Personal Care Manager will help you coordinate the services you may need, like rides to doctor appointments, and answer questions about staying healthy and more. It's your doctor, hospital and prescription drug coverage and independent living support in one simple plan.

- $0 copay for eyewear (up to $125 annually)
- $0 copay for dental fillings and dentures
- $0 copay for rides to doctor appointments
- $0 copay for all prescribed medications

Get more benefits in one plan at no cost to you.

Find out more today.
Call **1-888-727-8595,** TTY: **711,** or go to **UHCCommunityPlan.com.**

UnitedHealthcare®
Community Plan

UnitedHealthcare Senior Care Options (UnitedHealthcare SCO) is a voluntary program available to people who are 65 and older. UnitedHealthcare SCO is a Coordinated Care plan with a Medicare Advantage contract and a contract with the Commonwealth of Massachusetts Medicaid program. The benefit information provided herein is a brief summary, not a comprehensive description of benefits. For more information contact the plan.

MASCO 120213_173411
H2226_120213_173411 CMS Accepted

CST2965_240590